# ဗြးဗုဒ္ဓ

# ចំពូកទី ១

# ព្រះពុទ្ធសក្យមុនី

I

## ពុទ្ធប្បវត្តិ

1. ***ក្រុងកបិលពស្តុ*** *ជារាជធានីនៃកុលសម្ព័ន្ធសក្យ ស្ថិតនៅជើងភ្នំហិមពាន្ត ក្នុងជម្ពូទ្វីបភាគខាងជើង នាមាត់ស្ទឹង**រោហិនី**។ **ព្រះមហាក្សត្រសុទ្ធោទនៈ** ទ្រង់បានសាងមហាប្រាសាទមួយដ៏ល្អវិចិត្រ និងគ្រប់គ្រងប្រជាពលរដ្ឋដោយព្រហ្មវិហារធម៌។ ព្រះអង្គ ត្រូវបានជាទីនិយមរាប់អាននៃប្រជានុរាស្ត្រគ្រប់ជាន់ថ្នាក់។*

*ព្រះអគ្គមហេសី ទ្រង់ព្រះនាម **មហាមាយារាជទេវី** ។ ព្រះនាងជាព្រះរាជបុត្រីរបស់ព្រះបិតុលា នៃព្រះមហាក្សត្រដែលសោយរាជ្យនៅនគរជាប់គ្នា ក្នុងកុលសម្ព័ន្ធសក្យជាមួយគ្នា។*

*ក្នុងរយៈម្ភៃឆ្នាំ ព្រះមហាក្សត្រ ទ្រង់គ្មានព្រះរាជបុត្រ*

សោះ។ ទិវាមួយនោះ ព្រះអគ្គមហេសីទ្រង់យល់សប្តិឃើញដំរីសមួយ ចូលទៅក្នុងផ្ទៃព្រះនាងពីខាងស្តាំ។ បន្ទាប់មក ព្រះនាងក៏ទ្រង់គភ៌។ ព្រះមហាក្សត្រ និងប្រជាពលរដ្ឋត្រេកអរជាពន្លឹក។ តាមប្រពៃណី ព្រះអគ្គមហេសីទ្រង់ត្រឡប់ទៅនគរមាតាបិតាព្រះនាងវិញដើម្បីប្រសូត្របុត្រ។ នៅតាមផ្លូវ ព្រះនាងទ្រង់ចូលទៅសម្រាកព្រះកាយក្នុង**សួនលុម្ពិនី**។

**សួនលុម្ពិនី** នានិទាឃរដូវ ពោរពេញទៅដោយផ្កាអសោក។ គ្រាដែលព្រះនាង ឈោងព្រះហស្តស្តាំទៅកាច់ផ្កាមួយទងព្រះរាជបុត្រក៏ទ្រង់ប្រសូតមក។ មេឃ ដី និងសត្វលោកទាំងអស់ សែនមហាសប្បាយនឹងតព្វណ្ណាវង្សីនៃព្រះអគ្គមហេសីនិងព្រះរាជបុត្រព្រះនាង។ ទិវាមហាពន្លឹកនោះត្រូវជាថ្ងៃទី០៨ ខែមេសា។

ព្រះមហាក្សត្រទ្រង់ព្រះអំណរជាទីបំផុត។ ទ្រង់ដាក់ព្រះនាមព្រះរាជបុត្រព្រះអង្គថា **សិទ្ធត្ថៈ** ដែលមានន័យថា «សម្រេចបានគ្រប់សេចក្តីប្រាថ្នា»។

2. ប៉ុន្តែប៉ុន្មានថ្ងៃក្រោយ បន្ទាប់ពីការសប្បាយរីករាយមក

សេចក្តីទុក្ខព្រួយក៏ត្រូវកើតមានឡើងនៅក្នុងព្រះបរមរាជវាំង ដោយព្រះអគ្គមហេសី **សិរិមហាមាយា** ជាទីស្នេហាទ្រង់សោយទិវង្គតទៅយ៉ាងទាន់ហន់។ អនុជក្សត្រីរបស់ព្រះនាង ព្រះនាម **មហាប្រជាបតី** ក៏ទទួលបីបាច់រក្សាព្រះរាជកុមារ ដោយព្រះទ័យប្រោសប្រណី។

នៅគ្រានោះ មានតាបសឥសីមួយព្រះអង្គឈ្មោះ **អសិត** រស់នៅក្នុងព្រៃភ្នំជិតព្រះបរមរាជវាំងនោះ បានសង្កេតឃើញមានពន្លឺរស្មីចែងចាំងឡើងព័ទ្ធជុំវិញព្រះរាជដំណាក់។ តាបសឥសីនោះកាត់យល់ថា ជាប្រផ្នូលមួយវិសេសអស្ចារ្យ លោកក៏ចុះចាកពីភ្នំទៅព្រះបរមរាជវាំង ដើម្បីទតរាជកុមារ។ លោកក៏បានទស្សន៍ទាយថា: «បើព្រះកុមារទ្រង់គង់នៅក្នុងព្រះរាជវាំង ព្រះរាជកុមារនឹងបានទៅជាមហាចក្រពត្រាធិរាជ គ្រប់គ្រងពិភពលោកទាំងមូល។ តែបើប្រសិនជាព្រះកុមារនោះលះបង់រាជសម្បត្តិដើម្បីកាន់យកនូវជីវភាព ជាសាសនិក ព្រះអង្គនឹងបានជាព្រះពុទ្ធមួយអង្គ ជាអ្នកដោះទុក្ខពិភព-លោក»។

មុនដំបូង ព្រះមហាក្សត្រទ្រង់សព្វព្រះរាជហឫទ័យណាស់

ក្នុងការដែលទ្រង់បានជ្រាបអំពីទំនាយនេះ។ ប៉ុន្តែក្រោយបន្ទិចមក ព្រះរាជាទ្រង់ចាប់មានការព្រួយបារម្ភអំពីយថាភាពនៃព្រះរាជបុត្រតែមួយព្រះអង្គរបស់ព្រះអង្គ ដែលថ្ងៃណាមួយនឹងចាកចេញពីព្រះរាជវាំង ហើយនឹងទៅជាតាបសឥតសីឥតទីលំនៅខ្ជាប់ខ្ជួន។

នៅព្រះជន្មាយុបាន៧វស្សា ព្រះរាជកុមារទ្រង់បានចាប់ផ្ដើមសិក្សាវិជ្ជាគ្រប់គ្រងរដ្ឋ និងយោធាសាស្ត្រ។ តែមនោគតិរបស់ព្រះអង្គ បានត្រូវកែសំដៅទៅកាន់វត្ថុផ្សេងទៀត។ ថ្ងៃមួយនាទិទាយរដូវ ព្រះរាជកុមារបានយាងចេញអំពីព្រះរាជវាំងជាមួយនឹងព្រះបិតា និងព្រះរាជបរិពារ ទ្រង់បានទតឃើញកសិករម្នាក់កំពុងភ្ជួរដី។ ក្នុងពេលនោះ ព្រះរាជកុមារបានសង្កេតឃើញ បក្សីមួយហើរចុះអំពីអាកាសវេហាស៍មកហើយចឹកឆក់យកដង្កូវតូចមួយ ដែលផាលនង្គ័លធ្លឹះត្រឡប់ចេញពីក្នុងដីមក។ ព្រះរាជកុមារទ្រង់អង្គុយក្រោមដើមឈើមួយ ហើយទ្រង់ព្រះសញ្ជឹងគិតតែមួយព្រះអង្គឯងថាៈ «ឱ ! សត្វលោកដែលមានជីវិតរស់នៅៗ ឡើយនោះ ទីបំផុតត្រូវតែសម្លាប់គ្នាទៅវិញទៅមកដូច្នេះឬ ? »។

កាលនោះ ព្រះរាជកុមារ ដែលត្រូវបាត់បង់ព្រះមាតា យ៉ាងឆាប់ក្រោយពីទ្រង់ប្រសូតបានបន្តិចមកដូច្នេះ ទ្រង់មានសេចក្ដីសង្វេគចំពោះវិនាសកម្មនៃសត្វល្អិតទាំងពីរនោះ។

ឫសនៃដួងហឫទ័យរបស់ព្រះអង្គ ក៏ចេះតែជ្រៅឡើងៗក្នុងពេលដែលព្រះអង្គទ្រង់បានព្រះជន្មចម្រើនឡើង។ ដូចជាសម្ងាកដែលមាននៅក្នុងកូនឈើ ទុក្ខនៃជីវិតជាមនុស្សជាតិក៏ចាក់ឫសកាន់តែជ្រៅឡើងៗ ទៅក្នុងដួងព្រះហឫទ័យ។

ព្រះមហាក្សត្រជាបិតា ទ្រង់ព្រួយបារម្ភកាន់តែខ្លាំងឡើងៗ ដោយទំនាយព្រះតាបសឥសី ហើយទ្រង់បានខំតាមដោយគ្រប់មធ្យោបាយ ដើម្បីធ្វើឲ្យព្រះរាជកុមារ ទ្រង់សប្បាយរីករាយ ហើយបែរអារម្មណ៍ទៅគិតអំពីរឿងផ្សេងទៀត។ ក្នុងពេលព្រះរាជកុមារបានព្រះជន្មាយុ ១៩ ព្រះវស្សា ព្រះរាជាទ្រង់បានរៀបអភិសេកព្រះរាជបុត្រ ជាមួយនឹងព្រះរាជធីតាមួយព្រះអង្គព្រះនាម **យសោធរៈ** ជាបុត្រីនៃ**ព្រះបាទសុប្បពុទ្ធ** ដែលជាព្រះអធិរាជនៃក្រុង**ទេវទហៈ** និងជាព្រះរៀមបង្កើតរបស់ព្រះមហាក្សត្រិយានី **សិរិមហាមាយា**។

3. ក្នុងរយៈពេលដប់ឆ្នាំ ព្រះរាជកុមារ ទ្រង់បានទទួលការរីករាយសប្បាយនឹងភ្លេង របាំ និងការកំសាន្តផ្សេងៗ នារាល់និទាឃរដូវ សរទរដូវ និងរដូវភ្លៀងធ្លាក់ តែចិន្តារបស់ព្រះអង្គតែងតែវិលត្រឡប់មកគិតអំពីបញ្ហាទុក្ខ ជានិច្ចពុំដែលដាច់។ ហើយព្រះអង្គតែងតែខំប្រឹងប្រែងរកឲ្យយល់នូវ ការពិតអំពីន័យរបស់ជីវិតនៃសត្វលោក។

ទ្រង់គិតពិចារណាថា: «ប្រណីតភាពនៃព្រះរាជវាំង សុខភាពនៃរូបកាយ ការសប្បាយគ្រប់យ៉ាងនៃយុវភាព តើសេចក្ដីទាំងអស់នេះ មានន័យអ្វីចំពោះអាត្មាអញ»?។ «ថ្ងៃណាមួយអាត្មាអញនឹងមានជំងឺ នឹងដល់នូវជរាព្យាធិ ហើយនឹងចៀសពុំផុតអំពីការស្លាប់ទេ ! ការសប្បាយភ្លើតភ្លើននឹងយុវភាព និងសុខភាព និងអត្ថិភាព (ជីវិតរស់នៅ) សត្វលោកដែលមានសុភនិច្ឆ័យ គួរតែទុកសេចក្ដីទាំងអស់នេះមួយអន្លើ ! »។

«បុគ្គលដែលតស៊ូដើម្បីជីវិតរបស់ខ្លួន តែងតែស្វែងរក អ្វីដែលមានសារៈសំខាន់ជាធម្មតា។ រីឯការស្វែងរកសារៈវត្ថុនេះមានពីរយ៉ាងគឺ: ផ្លូវត្រូវ និងផ្លូវខុស។ ផ្លូវខុស គឺយ៉ាងនេះ : កាលណាគេសម្គាល់ឃើញថា ជំងឺ ជរា និងមរណៈ ជាការ

ចៀសពុំផុតហើយ ហើយស្វែងរកសារៈវត្ថុនៅក្នុងវត្ថុដែលមានសភាពទទេ ដែលមិនឋិតថេរដែរនុ៎ះ។

ផ្លូវត្រូវក្នុងការស្វែងរកសារៈវត្ថុនោះគឺៈ កាលណាគេដឹងថា ជំងឺ ជរា និងមរណៈ ជាការពិតក្នុងធម្មជាតិ គេត្រូវតែស្វែងរកសារៈវត្ថុនៅក្នុងវត្ថុណា ដែលហួសផុតពីទុក្ខវេទនាទាំងនោះរបស់មនុស្សលោក។ ក្នុងជីវភាពសប្បាយរីករាយក្នុងវាំងប្រាសាទរបៀបនេះ អាត្មាអញដូចជាស្វែងរកសារៈវត្ថុក្នុងផ្លូវខុស»។

4. ហេតុដូច្នេះហើយ បានជាការប្រយុទ្ធខាងផ្លូវចិត្តនៃរាជ-កុមារបានកើតមានឡើងក្នុងព្រះហឫទ័យ រហូតដល់ព្រះអង្គបានព្រះជន្ម២៩ព្រះវស្សា គឺក្នុងពេល **រាហុលកុមារ** ដែលត្រូវជាព្រះរាជបុត្រតែមួយរបស់ព្រះអង្គ ទ្រង់ប្រសូត្រឡើង។ ព្រឹត្តិការណ៍មួយដ៏ធំរកទីបំផុតគ្មាន ក៏បានកើតឡើង គឺព្រះរាជ-កុមារទ្រង់សម្រេចព្រះហឫទ័យចាកចោលព្រះរាជវាំង ហើយស្វែងរកការដោះស្រាយដំណើរជ្រួលច្របល់ចិត្ត ក្នុងភាពជាស្មូមដែលឥតទីលំនៅស្នាក់អាស្រ័យ។ គឺក្នុងរាត្រីកាល ដែល

ព្រះរាជកុមារ ទ្រង់ចាប់ប្រតិបត្តិគោលបំណងរបស់ព្រះអង្គនោះ ៖ ព្រះអង្គបានចាកចេញពីព្រះរាជដំណាក់ ដោយយកតាមព្រះអង្គនូវសារថីតែម្នាក់គត់ឈ្មោះ **ឆន្ន** ហើយទ្រង់គង់អាជានេយ្យជាទីសំណប់របស់ព្រះអង្គ សម្បុរសស្គុសដូចផ្កាទឹកកក ឈ្មោះ **កណ្ឋកៈ** ចាកចេញទៅ។

នៅពេលនោះ កង្វល់មិនបានរលាយបាត់អស់ពីព្រះឱរាទេ អារក្ស បិសាចជាច្រើន បានសាកល្បងព្រះអង្គដោយនិយាយថាៈ «ព្រះរាជាគួរតែវិលត្រឡប់ទៅព្រះរាជវាំងវិញ ហើយរកការដោះស្រាយតាមផ្លូវផ្សេងទៀតល្អជាងៈ បើធ្វើយ៉ាងនេះវិញ ពិភពលោកទាំងមូល ពិតនឹងទៅជាសម្បត្តិទ្រព្យរបស់ព្រះអង្គមិនខាន»។ តែព្រះអង្គទ្រង់ធ្វើឲ្យសំឡេងបិសាចទាំងនោះស្ងប់ស្ងាត់ទៅវិញបាន ដោយព្រះអង្គទ្រង់បានសម្រេចចិត្តថា ក្នុងលោកនេះ គ្មានអ្វីដែលអាចធ្វើឲ្យអង្គអញពេញចិត្តបានទេ។ កាលនោះព្រះអង្គទ្រង់បានកោរព្រះកេសា រួចហើយឈានព្រះបាទធ្វើដំណើរតម្រង់ទៅទិសខាងត្បូង ដោយមានកាន់បាត្រមួយសម្រាប់ការបិណ្ឌបាតផង។

ជាដំបូងបង្អស់ ព្រះរាជាទ្រង់បានទៅជួបនឹង **ឥសីភគ្គវៈ**

ហើយសង្កេតមើលរបៀបប្រតិបត្តិតបៈនៃឥសីនោះ។ បន្ទាប់មក ព្រះអង្គបានទៅសំណាក់នៅនឹងអាចារ្យ **អាឡារកាឡាម** ហើយនឹងអាចារ្យ **ឧទ្ទករាមបុត្ត** ដើម្បីរៀនវិធីការនាស្មឹងស្មាធិ៍រកផ្លូវដើម្បីបានសម្រេចនិព្វាន តាមរបៀបព្រាហ្មណ៍ទាំងនោះ។ ប៉ុន្តែក្រោយពីនៅបម្រើព្រាហ្មណ៍ ហើយហាត់រៀនវិធីទាំងនោះបន្តិចមក ព្រះអង្គក៏បានយល់ និងជឿជាក់ថាៈ វិធីទាំងនោះពុំអាចនឹងនាំព្រះអង្គទៅកាន់ការត្រាស់ដឹងបានទេ។ ទីបំផុត ព្រះអង្គបានយាងឆ្ពោះទៅកាន់ដែន **មគធៈ** ហើយប្រតិបត្តិតបៈក្នុងព្រៃ **ឧរុវេលា** ដែលស្ថិតនៅនាមាត់ស្ទឹង **នេរញ្ជរា** ដែលហូរប្រេបនឹងប្រាសាទ **គយា** ។

5. របៀបហាត់ហ្វឹកហ្វឺនរបស់ព្រះអង្គតឹងរឹងជាទីបំផុត ដែលនឹងរកជឿពុំបាន។ ព្រះអង្គទ្រង់បានធ្វើឧបត្តិកម្មក្នុងវិចារណៈថាៈ «គ្មានតាបសឥសីណាមួយ ក្នុងអតីតកាលក្ដី ក្នុងបច្ចុប្បន្នកាលនេះក្ដី និងទៅក្នុងអនាគតកាលក្ដី ដែលបានប្រតិបត្តិ ឬកំពុងប្រតិបត្តិ ឬនឹងប្រតិបត្តិ ដោយភាពតឹងរឹងបំផុតជាងអាត្មាអញនេះទេ»។

តែព្រះរាជាទ្រង់ពុំអាចយាងទៅដល់គោលបំណង របស់ព្រះអង្គសោះ។ ប្រាំមួយឆ្នាំក្រោយពីពេលដែលព្រះអង្គបានសំណាក់នៅក្នុងអរញ្ញព្រឹក្សនោះមក ព្រះរាជាក៏ទ្រង់លាចាកគ្រប់ការប្រតិបត្តិតបៈទាំងអស់។ ព្រះអង្គទ្រង់យាងទៅស្រង់ទឹកក្នុងស្ទឹង ហើយទ្រង់បានទទួលទឹកដោះគោមួយចានអំពីនាង**សុជាតា** ដែលជាទាសីម្នាក់រស់នៅក្នុងភូមិជិតទីនោះ។

អ្នកតាមដង្ហែព្រះអង្គប្រាំនាក់ ដែលរស់នៅប្រតិបត្តិតបៈជាមួយនឹងព្រះអង្គក្នុងរយៈប្រាំមួយឆ្នាំនោះ ក៏ទាស់ចិត្តយ៉ាងខ្លាំង នឹងការដែលបានឃើញព្រះអង្គទទួលយកទឹកដោះគោអំពីដៃទាសីនោះ។ អ្នកទាំងនោះបានគិតថា ព្រះអង្គប្រាស់ចាកសីលធម៌ហើយ ហើយក៏រត់ចោលព្រះអង្គអស់ទៅ។

យ៉ាងនេះ ព្រះរាជាក៏នៅតែមួយព្រះអង្គឯង។ ព្រះអង្គនៅខ្សោយព្រះកាយនៅឡើយ។ តែព្រះអង្គ ទ្រង់ល្បងធ្វើការភាវនាជាថ្មីទៀត ដោយឥតខ្លាចការអស់ព្រះជន្មឡើយ។ ទ្រង់និយាយទៅកាន់ព្រះអង្គឯងថាៈ «ទោះបីឈាមរបស់អាត្មាអញត្រូវរីងស្ងួតអស់ក៏ដោយ សាច់របស់អាត្មាអញត្រូវរហែករយះរយាយអស់ក៏ដោយ ឆ្អឹងរបស់អាត្មាអញ ត្រូវ

ផុយធ្លាក់ជាធូលីក៏ដោយ អាត្មាអញនឹងមិនចាកចេញពីកន្លែងនេះទេ ដរាបណាអាត្មាអញរកផ្លូវនៃការបានត្រាស់ដឹងមិនទាន់ឃើញ»។

កាលនោះ ព្រះអង្គបានប្រយុទ្ធពុះពារយ៉ាងខ្លាំងក្លាបំផុតដែលមិនអាចរកអ្វីមកប្រៀបផ្ទឹមបាន។ ឱរព្រះអង្គពោរពេញទៅដោយការអស់សង្ឃឹម និងអារម្មណ៍ច្របូកច្របល់។ វិញ្ញាណព្រះអង្គត្រូវបានគ្របដណ្តប់ដោយអន្ធភាពងងឹតស្លុង ។ ព្រះអង្គត្រូវខ្មោចព្រាយបិសាចទាំងឡាយឡោមព័ទ្ធ ហើយបញ្ឆោតលួងលោមគ្រប់បែបយ៉ាង។ តែព្រះអង្គទ្រង់យកការបញ្ឆោតលួងលោមទាំងនោះមកពិចារណាយ៉ាងហ្មត់ចត់ និងយ៉ាងអត់ធ្មត់មួយម្តងៗ ហើយទាត់ចោលទៅជាបន្តបន្ទាប់គ្នា។ គឺពិតជាការប្រយុទ្ធដ៏មហាពិបាកៈ លោហិតព្រះអង្គត្រូវជ្រាបចេញមក សាច់ព្រះអង្គត្រូវរបេះធ្លាក់ ឆ្អឹងរបស់ព្រះអង្គត្រូវប្រេះបាក់។

តែនៅពេលដែលផ្កាយព្រឹករះឡើងពីទិសខាងកើត ការប្រយុទ្ធក៏បានចប់។ វិញ្ញាណរបស់ព្រះរាជាក្លាយចែងចាំងឡើងដូចពន្លឺព្រះអាទិត្យដែលចាប់ផ្តើមរះឡើង។ ក្នុងទីបំផុត ព្រះ

*អង្គបានរកផ្លូវដើម្បីការបានត្រាស់ដឹងឃើញហើយ។ គឺនៅថ្ងៃទី០៨ ខែធ្នូ ក្នុងគម្រប់ព្រះជន្ម ៣៥ ព្រះវស្សា ដែលព្រះរាជាទ្រង់បានត្រាស់ជាព្រះពុទ្ធ។*

6. *ចាប់ពីពេលនោះមក ព្រះរាជាត្រូវបានគេស្គាល់ព្រះអង្គ ក្នុងនាមផ្សេងៗ ជាច្រើន។ អ្នកខ្លះហៅព្រះអង្គ ថា* ***ព្រះពុទ្ធ*** *អ្នកខ្លះទៀតដាក់ព្រះនាមព្រះអង្គថា* ***សក្យមុនី*** *អ្នកខ្លះទៀតហៅព្រះអង្គថា* ***អ្នកត្រាស់ញាណគ្រប់សព្វ*** *អ្នកខ្លះហៅព្រះអង្គថា* ***ព្រះសក្យមុនីមហាបណ្ឌិតនៃសក្យវង្ស*** *ជាសម្រេច អ្នកខ្លះផ្សេងទៀតឲ្យព្រះនាមព្រះអង្គថា* ***បុគ្គលជាទីគោរពបូជា*** *ក្នុងលោក។*

*ជាដំបូង ព្រះអង្គបាននិមន្តទៅដល់សួនឧទ្យាន**មិគទាយ** ក្នុងនគរ**ពារាណសី** ដែលព្រាហ្មណ៍ទាំងប្រាំនាក់ដែលបានរស់នៅជាមួយព្រះអង្គ កាលដែលព្រះអង្គទ្រង់ធ្វើទុក្ករកិរិយា ៦ ឆ្នាំ នោះរស់នៅ។ មុនដំបូង ព្រាហ្មណ៍ទាំងប្រាំនោះរកកលគេចចេញអំពីព្រះអង្គ។ តែក្រោយដែលព្រះអង្គបាននិយាយពន្យល់សព្វគ្រប់មក ព្រាហ្មណ៍ស្ទូមទាំងនោះក៏ជឿតាមព្រះ*

អង្គ ហើយបានទៅជាព្រះសាវ័ករបស់ព្រះអង្គ មុនគេបង្អស់នាកាលនោះទៅ។ បន្ទាប់មក ព្រះអង្គនិមន្តទៅដល់មហានគរ **រាជគ្រឹះ** ហើយព្រះអង្គបានញុំាំងឲ្យព្រះមហាក្សត្រ ព្រះនាម **ពិម្ពិសារ** ឲ្យជឿនូវសាសនាព្រះអង្គ។ គឺចាប់ពីកន្លែងនោះហើយ ដែលព្រះអង្គនិមន្តសុសសព្វទិសទីគ្រប់ជនបទ បិណ្ឌ-បាតចង្ហាន់ ហើយណែនាំពន្យល់អ្នកស្រុកទាំងឡាយ ឲ្យជឿនូវធម៌របស់ព្រះអង្គ។

មហាជនបានជឿតាមព្រះអង្គ បីដូចជាមនុស្សស្រេកទឹកហើយរត់រកទឹកផឹក ឬបីដូចមនុស្សដែលឃ្លានហើយរត់រកអាហារបរិភោគ។ មហាសាវ័កពីរព្រះអង្គព្រះនាម **ព្រះសារីបុត្ត**១ និង **ព្រះមោគ្គលាន**១ បានដង្ហែព្រះអង្គ ជាមួយនឹងសិស្សពីរពាន់នាក់។

មុនដំបូង ព្រះបាទ**សុទ្ធោទនៈ** ដែលត្រូវជាព្រះបិតារបស់ព្រះពុទ្ធ ដោយទ្រង់នៅមានព្រះទ័យក្រៀមក្រំនៅឡើយនឹងការដែលព្រះរាជបុត្រចាកចោលព្រះបរមរាជវាំង ព្រះអង្គពុំបានចូលព្រះទ័យទេ។ តែដល់ក្រោយមក ព្រះអង្គក៏ត្រឡប់ទៅជាអ្នកជឿតាមព្រះពុទ្ធម្នាក់ដ៏ស្មោះស្ម័គ្រ។

ព្រះនាង **មហាប្រជាបតី** ដែលជាព្រះមាតុច្ឆា និងជាមាតាចិញ្ចឹមរបស់ព្រះពុទ្ធ, ព្រះនាង **យសោធរា** ដែលជាព្រះមហេសីរបស់ព្រះអង្គ និងព្រះញាតិទាំងអស់ក្នុងវង្សសក្យ ក៏ជឿតាមព្រះអង្គ។ មនុស្សជាច្រើនទៀតក៏ជឿតាមព្រះអង្គយ៉ាងស្មោះដែរ។

7. ក្នុងរយៈ ៤៥ ឆ្នាំ ព្រះពុទ្ធទ្រង់និមន្តសុសសព្វក្នុងភូមិប្រទេសនានា ដើម្បីសម្តែងធម្មទេសនា និងពន្យល់ប្រជាជនឲ្យយល់ហើយប្រតិបត្តិតាមរបៀបរស់នៅរបស់ព្រះពុទ្ធអង្គ។ ក្នុងទីបំផុត គឺក្នុងព្រះជន្មបាន ៨០ ព្រះវស្សា នៅពេលព្រះអង្គនិមន្តទៅដល់នគរ **វេសាលី** ក្នុងលំដាប់ផ្លូវដែលព្រះអង្គនិមន្តពី**រាជគ្រឹះ** ទៅ**សាវត្ថី** ព្រះអង្គក៏ធ្លាក់មានអាពាធ ហើយព្រះអង្គទ្រង់ទាយទុកថា ក្នុងបីខែទៅមុខនេះព្រះអង្គនឹងចូលព្រះនិព្វាន។ ព្រះអង្គទ្រង់បន្តដំណើរទៅទៀតទៅដល់នគរ**បាវា**។ នៅទីនោះ ព្រះអង្គទ្រង់អាពាធរឹតតែខ្លាំងឡើងៗ នៅក្រោយពេលដែលព្រះអង្គឆាន់ចង្ហាន់ដែលជាងដំដែកម្នាក់ឈ្មោះ**ចុន្ទៈ** បានប្រគេន។ បន្ទាប់មក ដោយការខិតខំបន្តិចម្តងៗ ទោះបីជាមានការឈឺចាប់ និងការខ្សោយព្រះកាយពលជា

ខ្លាំងក៏ដោយ ព្រះអង្គបាននិមន្តទៅដល់ព្រៃ ដែលស្ថិតនៅជាយក្រុង**កុសិនារា**។

នៅទីនោះ ព្រះអង្គទ្រង់ទម្រេតព្រះកាយនាកណ្ដាលសាលព្រឹក្សធំៗពីរដើម ហើយព្រះអង្គទ្រង់បន្តការប្រៀនប្រដៅដល់សាវ័កទាំងឡាយរបស់ព្រះអង្គ រហូតដល់ព្រះអង្គសុគតទៅ។ នៅទីបំផុត ក្រោយពេលដែលព្រះអង្គបានបំពេញករណីយកិច្ចជាគ្រូអាចារ្យធំបំផុតនៃមនុស្សលោក និងជាទីស្រឡាញ់បំផុតនៃបុគ្គលគ្រប់រូប ព្រះអង្គក៏បានយាងទៅកាន់ស្ថានបរមសុខ គឺឋានសូប់គ្មានទីបំផុត។

8. នៅក្រោមការដឹកនាំរបស់**ព្រះអានន្ទ** ដែលជាសាវ័កសំណាប់បំផុតរបស់ព្រះអង្គ ពុទ្ធបរិស័ទទាំងឡាយបានព្រមព្រៀងគ្នាសម្រេចធ្វើឈាបនកិច្ចសពព្រះពុទ្ធ នៅក្រុង**កុសិនារា**នោះទៅ។

ព្រះបាទ **អជាតសត្តុ** និងអធិរាជប្រាំពីរអង្គទៀត ដែលសោយរាជ្យនៅនគរជាប់គ្នានោះ បានសុំឲ្យចែករំលែកព្រះពុទ្ធសារីរិកធាតុរវាងគ្នា និងគ្នា។ មុនដំបូង ព្រះមហាក្សត្រ

នៃក្រុង**កុសិនារា** ទ្រង់ប្រឆាំងនឹងសេចក្តីស្នើនេះ ដែលជាហេតុមួយបម្រុងនឹងនាំឲ្យមានចម្បាំងផ្ទុះឡើង។ តែដល់ក្រោយមកលុះដោយឱវាទរបស់មហាបណ្ឌិតម្នាក់ឈ្មោះ **ទោណៈ** ការទាស់ទែងគ្នានោះក៏រលាយទៅវិញ ហើយព្រះសារីរិកធាតុ ក៏ត្រូវបានចែកគ្នា រវាងប្រាំបីព្រះរាជាណាចក្រនោះទៅ។ ព្រះសារីរិកធាតុ និងថូដីដាក់ធាតុ ត្រូវបានចែករំលែកទៅព្រះមហាក្សត្រពីរនគរផ្សេងទៀត ដើម្បីជាទីសក្ការៈបូជា។ ហេតុនេះហើយបានជា ស្តូបវិមានជាទីរំលឹកដល់ ព្រះពុទ្ធជាម្ចាស់ត្រូវបានកសាងឡើងជាច្រើន ដើម្បីតម្កល់ព្រះសារីរិកធាតុនៃព្រះពុទ្ធអង្គ។

II

# ឱវាទចុងក្រោយរបស់ព្រះពុទ្ធ

1. នៅពេលដែលព្រះអង្គផ្ទួលដេកកណ្តាលសាលព្រឹក្ស នាក្រុង**កុសិនារា**នោះ ព្រះពុទ្ធជាម្ចាស់ ទ្រង់មានព្រះពុទ្ធដីកាជាចុងក្រោយបង្ហើសទៅកាន់ព្រះសាវ័កថា:

«ចូរអ្នកជាប្រទីបបំភ្លឺខ្លួនឯង ចូរអ្នកជួយខ្លួនឯង ចូរអ្នកកុំ

រស់ដោយសារអ្នកដទៃ។ ចូរឲ្យការប្រៀនប្រដៅរបស់តថាគត ជាប្រទីបរបស់អ្នក និងជាទីពំនឹងរបស់អ្នក។ ចូរកុំយោលទៅ តាមការប្រៀនប្រដៅរបស់អ្នកផ្សេងទៀត»។

«ចូរក្រឡេកមើលទៅរូបរបស់អ្នក តើវាមានសភាពមិន បរិសុទ្ធយ៉ាងណា! ដឹងច្បាស់ហើយថា សេចក្តីសប្បាយរីករាយ និងសេចក្តីទុក្ខគ្រាំគ្រានៃរូបកាយ ជាមូលហេតុនៃការឈឺចាប់ នោះ តើអ្នកអាចបណ្តាលឲ្យរូបកាយនោះ វាបំពេញបំណងវា បានដោយសេរីបានឬ ? ចូរក្រឡេកមើលទៅវិញ្ញាណរបស់អ្នក តើវាផ្លាស់ប្តូរប៉ុន្មានដង? ក្នុងពេលដែលអ្នកដឹងថា មនោ-សញ្ចេតនាទាំងនោះ ច្បាស់ជានឹងនាំអ្នកទៅកាន់សេចក្តី វេទនា តើអ្នកអាចបណ្តោយខ្លួនឲ្យធ្លាក់ទៅក្នុងសេចក្តីភ័ន្តច្រឡំ គំនិត ហើយប្រកាន់យកអភិមានះ និងអត្តទត្តភាពបានឬទេ? ចូលក្រឡេកមើលទៅវត្ថុជាតុគ្រប់ទាំងអស់នៅលើលោកនេះ ចុះ តើអ្នកអាចសម្គាល់ឃើញវត្ថុណាដែលឋិតថេរដែរឬទេ ? តើអ្នកសម្គាល់ឃើញថា វត្ថុទាំងនោះ វាគ្រាន់តែជាការ ប្រមូលផ្តុំភ្ជាប់គ្នានៃវត្ថុជាតុឯទៀតៗ ដែលយូរឬឆាប់ នឹងត្រូវ តែបែកបាក់គ្នា ហើយបែកខ្ញែកគ្នាជាពុំខាននោះដែរឬទេ ?

ប៉ុន្តែចូរកុំមានការភិតភ័យដោយសារតែបានសម្គាល់ឃើញថា វត្ថុអ្វីៗក៏ជាទុក្ខវេទនានោះ ចូរធ្វើតាមការប្រៀនប្រដៅរបស់តថាគតជានិច្ច ទោះបីក្រោយពេលតថាគតអស់សង្ខារទៅហើយក្តី។ បើអ្នកប្រតិបត្តិតាមឱវាទតថាគត អ្នកមុខជាចាកផុតអំពីទុក្ខ ហើយអ្នកនឹងពិតជាសាវ័ករបស់តថាគតជាពុំខាន។

2. «ម្នាលភិក្ខុទាំងឡាយ! សេចក្តីប្រៀនប្រដៅ ដែលតថាគតបានផ្តល់ឲ្យអ្នកទាំងប៉ុន្មាន ចូរអ្នកកុំភ្លេចឲ្យសោះ ហើយនិងកុំឲ្យបាត់បង់ឲ្យសោះ។ អ្នកត្រូវតែជញ្ជឹងគិតចំពោះការប្រៀនប្រដៅទាំងនោះ ជានិច្ច ហើយត្រូវតែប្រតិបត្តិតាមជានិច្ចនិរន្តរ៍។ បើអ្នកធ្វើតាមការប្រៀនប្រដៅរបស់តថាគត អ្នកនឹងបានប្រកបដោយសុភមង្គលជានិច្ចកាល»។

«សារៈសំខាន់ក្នុងការប្រៀនប្រដៅរបស់តថាគត គឺអ្នកត្រូវតែត្រួតត្រាបំពត់ចិត្តរបស់អ្នក។ អ្នកត្រូវតែលះបង់ការលោភលន់ ហើយធ្វើខ្លួនអ្នកឲ្យត្រង់ ធ្វើចិត្តអ្នកឲ្យបរិសុទ្ធ និងប្រកាន់ពាក្យសម្តីអ្នកឲ្យស្មោះត្រង់។ បើអ្នកជញ្ជឹងគិតជានិច្ច

ថា ជីវិតរបស់អ្នកវាមានសភាពមិនឋិតថេរ នោះអ្នកមុខជានឹងអាចចៀសផុតពីការលោភលន់ និងការមានកំហឹង ហើយអ្នកនឹងអាចចៀសផុតពីទុក្ខគ្រប់យ៉ាងបាន។

«បើអ្នកសង្កេតឃើញថា ចិត្តរបស់អ្នកវាមានចំណង់ ហើយធ្លាក់ទៅក្នុងសេចក្ដីលោភលន់ អ្នកត្រូវតែបំបាត់ចោលសេចក្ដីលោភលន់នោះ ហើយត្រួតត្រាទប់ចំណង់នោះ ចូរអ្នកតាំងខ្លួនអ្នកជាគ្រូនៃចិត្តរបស់អ្នក»។

«គឺចិត្តរបស់យើងផ្ទាល់នេះហើយ ដែលធ្វើឲ្យយើងបានជាព្រះពុទ្ធមួយអង្គ ឬក៏ធ្វើឲ្យយើងទៅជាសត្វធាតុមួយ។ បើយើងយល់ច្រឡំក្នុងការខុស យើងនឹងទៅជាបិសាច តែបើយើងភ្លឺស្វាង យើងនឹងបានជាព្រះពុទ្ធ។ ហេតុនេះ ចូរអ្នកត្រួតត្រាទប់ចិត្តរបស់អ្នក កុំឲ្យវាឃ្លាតចាកអំពីមាគ៌ាថ្លៃថ្នូរ។

3. «ដោយអនុលោមទៅតាមការប្រៀនប្រដៅ របស់តថាគត ចូរអ្នកត្រូវគេះគោរពគ្នាទៅវិញទៅមក ចូរអ្នកចៀសវាងការឈ្លោះប្រកែកគ្នា។ ចូរអ្នកកុំធ្វើត្រាប់ទឹក និងប្រេង ដែលរុញច្រានគ្នាទៅវិញទៅមកជានិច្ចនោះ តែចូរ

អ្នកធ្វើគ្រាប់តាមទឹក និងទឹកដោះ ដែលអាចរលាយចូលគ្នាបាន»។

«ចូរអ្នកសិក្សារៀនទាំងអស់គ្នា ចូរអ្នកបង្ហាត់បង្រៀនគ្នាទៅវិញទៅមក ចូរអ្នកធ្វើវត្តប្រតិបត្តិទាំងអស់គ្នា។ ចូរអ្នកកុំបំផ្លាញសតិរបស់អ្នក ហើយធ្វើឲ្យខាតពេលវេលារបស់អ្នកក្នុងភាពទំនេរ និងក្នុងការឈ្លោះទាស់ទែងគ្នា។ ចូរអ្នកទទួលត្រេកអររីករាយនឹងផ្កានៃការបានត្រាស់ដឹង ដែលរីកក្នុងរដូវ ហើយបេះយកផលនៃផ្លូវត្រូវ»។

«សេចក្តីប្រៀនប្រដៅទាំងប៉ុន្មាន ដែលតថាគត បានផ្តល់ដល់អ្នក គឺជាគតិអារម្មណ៍ដែលតថាគតទទួលបាន ដោយតថាគតបានដើរតាមផ្លូវនោះដោយខ្លួនឯង។ ចូរអ្នកធ្វើតាមការប្រៀនប្រដៅទាំងនោះ ហើយចូរអ្នកអនុលោមទៅតាមគ្រប់កាលៈទេសៈទាំងអស់»។

«បើអ្នកមិនរវល់យកចិត្តទុកដាក់នឹងការប្រៀនប្រដៅទាំងនេះ បានន័យថា អ្នកមិនដែលបានជួបនឹងតថាគត ដោយពិតគឺប្រាកដជាអ្នកនៅឆ្ងាយពីតថាគត ទោះបីនៅពេលនេះ អ្នកកំពុងអង្គុយជិតបង្កើយនឹងតថាគតក៏ដោយ។ តែផ្ទុយទៅវិញ បើអ្នកទទួលនឹងប្រតិបត្តិតាមការប្រៀនប្រដៅ របស់តថាគត

ទោះបីជាអ្នកនៅដល់ចុងម្ខាងទៀតនៃពិភពលោក ក៏ដោយ ក៏អ្នកហាក់ដូចជានៅជិតបង្កើយនឹងតថាគតដែរ»។

4. «ម្នាលភិក្ខុទាំងឡាយ! អវសានជីវិតរបស់តថាគតជិតមកដល់ហើយ ការបែកគ្នារវាងយើង ក៏កាន់តែជិតមកដល់ដែរ។ តែចូរអ្នកកុំមានទុក្ខសោកឡើយ។ ជីវិតគឺជាការផ្លាស់ប្តូរជានិច្ចនិរន្តរ៍ ហើយគ្មានអ្វីដែលអាចចៀសផុតពីការរលាយទៅវិញនៃរូបកាយទេ។ តថាគត នឹងបង្ហាញអ្នកទាំងឡាយឲ្យឃើញក្នុងរឿងនេះ នៅពេលឥឡូវនេះ ដោយការមរណៈផ្ទាល់របស់តថាគតនេះឯង រូបកាយរបស់តថាគតនឹងរលាយទៅ ដូចជារទេះដែលទ្រុឌទ្រោមដូច្នោះឯង»។

«ចូរកុំសោយសោកដោយឥតប្រយោជន៍នោះ ចូរអ្នកយល់ឲ្យច្បាស់ថា គ្មានអ្វីដែលឋិតថេរទេ ដូច្នេះហើយជីវិតមនុស្សក៏វាជាសភាពទទេ គ្មានអ្វីសោះយ៉ាងនោះដែរ។ ចូរកុំរក្សាចំណង់ដែលគ្មានទំនង ដោយសារតែយល់ឃើញថា អ្វីៗដែលមិនឋិតថេរ វាអាចទៅជាឋិតថេរនោះ»។

«បិសាចនៃចំណង់ទាំងឡាយក្នុងលោកនេះ រកគ្រប់មធ្យោបាយជានិច្ចកាល ដើម្បីនឹងបំភាន់សតិអ្នក។ បើសិនជាមានពស់វែករស់នៅក្នុងបន្ទប់របស់អ្នក អ្នកអាចដេកដោយសុខសាន្តបាន លុះត្រាតែអ្នកដេញពស់វែកនោះឲ្យចេញពីបន្ទប់អ្នករួចហើយ»។

«អ្នកត្រូវតែផ្ដាច់ចំណងនៃចំណង់លោកិយ ហើយបណ្ដេញវាចេញ ដូចជាអ្នកបានបណ្ដេញពស់វែកឲ្យចេញពីបន្ទប់យ៉ាងនោះដែរ។ អ្នកត្រូវតែការពារសតិរបស់អ្នកឲ្យមធ្យ័ត»។

5. «ម្នាលភិក្ខុទាំងឡាយ! ទីអវសានរបស់តថាគតមកដល់ហើយ តែចូលកុំភ្លេចថា សេចក្ដីមរណៈវាគ្រាន់តែជាការរលាយនៃរូបកាយតែប៉ុណ្ណោះទេ។ រូបកាយកើតឡើងពីមាតាបិតា ធំធាត់ឡើងដោយសារចំណីអាហារ តែអ្វីដែលរូបកាយមិនអាចចៀសផុតសម្រាប់រូបកាយគឺ ឈឺ និងស្លាប់»។

«ព្រះពុទ្ធពិតប្រាកដនោះ ពុំមែនជារូបកាយមនុស្សទេ ប៉ុន្តែគឺជាការបានត្រាស់ដឹងនោះឯង។ រូបកាយមនុស្ស ត្រូវតែរលាយបាត់បង់ជាធម្មតា តែព្រហ្មចារីភាពនៃការត្រាស់ដឹង ឋិតថេរជានិច្ចគ្មានទីបំផុត នៅក្នុងការពិតនៃព្រះធម្ម និង

ក្នុងការប្រតិបត្តិព្រះធម្ម។ អ្នកដែលឃើញតែរូបកាយរបស់តថាគត មិនបានឃើញតថាគតដោយពិតទេ។ មានតែអ្នកដែលទទួលយកការប្រៀនប្រដៅរបស់តថាគតទេ ដែលបានឃើញតថាគតដោយពិត។»។

«ក្រោយពេលដែលតថាគតអស់សង្ខារទៅ ព្រះធម្មនឹងទៅជាគ្រូរបស់អ្នក។ ចូរប្រតិបត្តិតាមព្រះធម្ម ធ្វើយ៉ាងនេះអ្នកនឹងបានទៅជាសាសនិកម្នាក់ដែលជឿតាមតថាគត»។

«ក្នុងជីវិតតថាគត ៤៥ ឆ្នាំនេះ តថាគតគ្មានបានលាក់ទុកអ្វីបន្តិចបន្តួចក្នុងការប្រៀនប្រដៅរបស់តថាគតទេ។ គ្មានអ្វីដែលជាការប្រៀនប្រដៅជាសម្ងាត់ទេ ក្នុងន័យលាក់លៀមក៏គ្មានដែរ។ អ្វីៗទាំងអស់ ត្រូវបានប្រៀនប្រដៅទៅដោយស្មោះត្រង់ និងច្បាស់លាស់។ សាវ័កជាទីស្រឡាញ់របស់តថា-គតទាំងឡាយអើយ! ពេលនេះជាអវសាននៃតថាគតហើយ។ បន្តិចទៀតនេះ តថាគតនឹងទៅកាន់និព្វានហើយ សេចក្តីទាំងនេះហើយ ជាការប្រៀនប្រដៅរបស់តថាគត»។

# ចំពូកទី ២

# ព្រះពុទ្ធអនន្ត និងប្រសើរបំផុត

## I

## សេចក្ដីអាសូរ និងពររបស់ព្រះពុទ្ធ

1. *ព្រះទ័យព្រះពុទ្ធ ពោរពេញទៅដោយមហាអាសូរ និង មហាករុណា។ ចិត្តមហាមេត្តាដែលពោរពេញទៅដោយ សេចក្ដីស្រឡាញ់ និងករុណា គឺជាការស្ម័គ្រចិត្តជួយដោះទុក្ខ សត្វលោកតាមគ្រប់មធ្យោបាយ។ ចិត្តមហាអាសូរ គឺជាចិត្ត ដែលរុញច្រានឲ្យឈឺជាមួយអ្នកជំងឺ ឲ្យកើតទុក្ខជាមួយអ្នក មានទុក្ខ។*

*«ទុក្ខរបស់អ្នក ជាទុក្ខរបស់តថាគត សុភមង្គលរបស់អ្នក ជាសុភមង្គលរបស់តថាគត»* នេះជាវាចារបស់ព្រះពុទ្ធ។ *យ៉ាង ណាមិញ ដូចជាមាតាដែលតែងតែស្នេហាបុត្រជានិច្ច។ ព្រះពុទ្ធ អង្គពុំដែលភ្លេចមនោគតិនេះទេ សូម្បីតែមួយភ្លែតក៏គ្មានដែរ ពីព្រោះជាធម្មជាតិរបស់ព្រះពុទ្ធ ដែលមានព្រះទ័យពោរពេញ ទៅដោយការអាណិតអាសូរ។*

ចិត្តអាណិតអាសូររបស់ព្រះពុទ្ធ យោលទៅតាមសេចក្ដីត្រូវការរបស់មនុស្សលោក។ ជំនឿរបស់បុគ្គល គឺជាប្រតិកម្មនៃចិត្តអាណិតអាសូររបស់ព្រះពុទ្ធនោះឯង។ ជំនឿនេះហើយដែលនាំឲ្យបុគ្គលនោះទៅកាន់ការត្រាស់ដឹង ប្រាកដដូចជាមាតាដែលបំពេញករណីយកិច្ចជាម្ដាយ ដោយសេចក្ដីស្នេហាបុត្ររបស់ខ្លួន។ យ៉ាងណាមិញ បុត្រនោះ ដោយមានប្រតិកម្មចំពោះសេចក្ដីស្រឡាញ់ស្មោះនៃមាតានោះ ក៏អស់មានការព្រួយបារម្ភ ហើយក៏មានអារម្មណ៍សុខស្រួលទៅ។

តែសត្វលោកមិនយល់ចិត្តរបស់ព្រះពុទ្ធ ហើយនៅតែរងទុក្ខវេទនាមិនចេះចប់ ដោយការកាន់គំនិតនឹងចំណង់ ដែលកើតឡើងពីសេចក្ដីល្ងង់ខ្លៅរបស់ខ្លួន។ សត្វលោកមានទុក្ខដោយអំពើផ្ទាល់របស់ខ្លួន ដែលប្រមូលផ្ដុំឡើងដោយសារតែតណ្ហាលោកិយ ហើយវង្វេងក្នុងគំនរគំនិតភាន់ច្រឡំ ដោយមានសំពាយមហាធ្ងន់មួយពេញទៅដោយអំពើអាក្រក់ ស្ពាយជាប់នឹងខ្លួនផង។

2. ចូរកុំគិតស្មានថា សេចក្ដីអាណិតអាសូររបស់ព្រះពុទ្ធ គឺ

សម្រាប់តែជីវិតបច្ចុប្បន្នតែប៉ុណ្ណោះនោះ។ សេចក្ដីអាណិតអាសូរ ដែលមិនមានកំណត់ពេលវេលារបស់ព្រះពុទ្ធអនន្តនោះ បានបញ្ចេញសកម្មភាពតាំងតែពីកាលដែលសត្វលោកធ្លាក់ក្នុងការវង្វេងគំនិត ដោយហេតុតែល្ងង់ខ្លៅនោះម៉្លេះ។

ព្រះពុទ្ធអនន្តបង្ហាញឲ្យឃើញ ស្ដែងឡើងជានិច្ចចំពោះមុខសត្វលោក ក្នុងភាពជាវរមិត្ត ហើយនាំយកមកផ្ដល់ឲ្យនូវរបៀបដោះទុក្ខភ័យដែលប្រកបដោយគតិបណ្ឌិតជាទីបំផុត។

ព្រះពុទ្ធសក្យមុនី ព្រះអង្គទ្រង់ប្រសូតក្នុងត្រកូលសក្យ ព្រះអង្គចាកចោលផាសុកភាពនៃព្រះរាជដំណាក់ ហើយទៅរស់នៅក្នុងភាពជាតាបសឥសី។ ដោយសារការស្មឹងស្មាធិ៍ភាវនាក្នុងភាពស្ងប់ស្ងាត់ ព្រះអង្គក៏បានត្រាស់ជាព្រះពុទ្ធ។ ព្រះអង្គបានសម្ដែងធម៌ទូន្មានមហាជន ដែលយកចិត្តទុកដាក់ស្ដាប់ត្រាប់ត្រង់តាមព្រះអង្គ ហើយក្នុងទីបំផុត ព្រះអង្គបានបង្ហាញឲ្យឃើញច្បាស់ ដោយការមរណៈរបស់ព្រះអង្គពីលោកនេះទៅ។

ភារកិច្ចរបស់ព្រះពុទ្ធគ្មានទីបំផុត ដូចជាសេចក្ដីល្ងង់ខ្លៅរបស់សត្វលោកគ្មានទីអវសានដូច្នោះដែរ។ ជម្រៅនៃសេចក្ដីល្ងង់ខ្លៅរបស់សត្វលោកវាជ្រៅគ្មានទីបំផុតយ៉ាងណា សេចក្ដី

អាណិតអាសូររបស់ព្រះពុទ្ធក៏គ្មានព្រំដែនយ៉ាងនោះដែរ។

ការដែលព្រះពុទ្ធកាត់ព្រះទ័យលះបង់ជីវិតលោកិយនេះ ព្រះអង្គបានធ្វើសេចក្ដីសច្ចាធំៗ បួនៈ ស្រោចស្រង់សត្វលោកទាំងអស់ លះបង់គ្រប់ការប្រាថ្នាក្នុងលោកិយទាំងអស់ រៀនគ្រប់សិក្ខាបទទាំងអស់ និងសម្រេចបាននូវការត្រាស់ដឹងឥតខ្ចោះកន្លែងណាមួយឡើយ។ សេចក្ដីសច្ចារបស់ព្រះអង្គទាំងនេះ បញ្ចេញឲ្យឃើញជាក់ឡើង តាមសេចក្ដីស្នេហានិងប្រណីអាសូរ ដែលជាលក្ខណៈសំខាន់បំផុតក្នុងសភាវៈរបស់ព្រះពុទ្ធ។

3. មុនដំបូងបង្អស់ ព្រះពុទ្ធហាត់រៀនឲ្យមានចិត្តល្អចំពោះគ្រប់សត្វលោកដែលមានជីវិតរស់នៅ ហើយចៀសវាងបាបកម្មដោយការសម្លាប់សត្វរស់ទាំងឡាយ។ ជាបន្ទាប់ ព្រះអង្គប្រាថ្នាឲ្យសត្វទាំងអស់ បានប្រកបតែសុភមង្គលក្នុងជីវិតដ៏វែងឆ្ងាយ។

ព្រះពុទ្ធទ្រង់បានហាត់រៀន ចៀសវាងការលួចប្លន់គេ ហើយព្រះអង្គទ្រង់មានប្រាថ្នាឲ្យសត្វលោកទាំងឡាយ អាចនឹងមានគ្រប់វត្ថុទាំងអស់ដែលខ្លួនត្រូវការ។

ព្រះពុទ្ធ ទ្រង់បានហាត់រៀនចៀសវាងអំពើអនាចារផិតក្បត់ គឺការធ្វើឲ្យខូចគុណសម្បត្តិ។ អាស្រ័យដោយបុណ្យបារមីនេះ ព្រះអង្គទ្រង់ប្រសិទ្ធពរឲ្យសត្វលោកទាំងឡាយអាចយល់នូវសេចក្តីសុខដែលកើតពីចិត្តបរិសុទ្ធ ហើយលែងមានទុក្ខ-ភ័យដែលកើតពីចំណង់ចង់បានមិនចេះស្កប់ស្កល់។

ព្រះពុទ្ធ ដោយមានប្រាថ្នាឲ្យបានសម្រេចឧត្តមគតិរបស់ព្រះអង្គ ព្រះអង្គបានហាត់រៀនវៀរចាកឲ្យផុតពីអំពើប្រវញ្ចន៍បោកបញ្ឆោតទាំងឡាយ។ អាស្រ័យដោយបុណ្យបារមីនេះ ព្រះអង្គទ្រង់ប្រសិទ្ធពរឲ្យសត្វទាំងឡាយអាចយល់នូវការស្ងប់នៃវិញ្ញាណ ដែលកើតឡើងអំពីសេចក្តីស្មោះត្រង់នៃចិត្ត និងវាចា។

ព្រះពុទ្ធ បានហាត់រៀនចៀសវាងការនិយាយពាក្យបោកបញ្ឆោត អាស្រ័យដោយបុណ្យបារមីនេះ ព្រះអង្គទ្រង់ប្រសិទ្ធពរ ឲ្យសត្វលោកទាំងឡាយ អាចយល់នូវសេចក្តីសប្បាយរីករាយ ដែលបានមកអំពីការចេះស្រឡាញ់រួបរួមគ្នា ហើយនាំគ្នាប្រតិបត្តិធ្វើតាមការប្រៀនប្រដៅរបស់ព្រះអង្គ។

ព្រះអង្គទ្រង់បានហាត់រៀនចៀសវាង ការប្រមាថរំលោក

លើអ្នកដទៃ ហើយព្រះអង្គទ្រង់ប្រសិទ្ធពរ ឲ្យសត្វលោកទាំងឡាយអាចប្រកបនូវសតិស្ងប់ ដែលកើតឡើងពីការចេះរស់នៅដោយសុខសន្តិភាពជាមួយនឹងអ្នកដទៃ។

ព្រះអង្គទ្រង់បានហាត់រៀនចៀសវាងការនិយាយគ្មានខ្លឹមសារ ហើយព្រះអង្គទ្រង់ប្រសិទ្ធពរ ឲ្យសត្វលោកទាំងឡាយអាចស្គាល់នូវសុភមង្គល ដែលកើតឡើងអំពីការចេះមានមេត្តាធម៌។

ព្រះពុទ្ធ ក្នុងបំណងឲ្យបានសម្រេចឧត្តមគតិរបស់ព្រះអង្គ គឺការបានត្រាស់ដឹង ទ្រង់បានហាត់រៀនវៀរចាកឲ្យផុតពីសេចក្តីលោភលន់។ អាស្រ័យដោយបុណ្យបារមីនេះ ព្រះអង្គទ្រង់ប្រសិទ្ធពរឲ្យសត្វលោកទាំងឡាយ អាចយល់នូវសុខសន្តិភាព ដែលកើតឡើងបានដោយសារការចេះវៀរចាកនូវសេចក្តីលោភលន់ទាំងឡាយ។

ព្រះអង្គទ្រង់បានហាត់រៀនចៀសវាងកំហឹង ហើយព្រះអង្គទ្រង់ប្រសិទ្ធពរឲ្យសត្វលោកទាំងឡាយ ចេះស្រឡាញ់គ្នាទៅវិញទៅមក។

ព្រះអង្គទ្រង់បានហាត់រៀនចៀសឲ្យផុតពីសេចក្តីល្ងង់ខ្លៅ

គឺអវិជ្ជា ហើយព្រះអង្គទ្រង់ប្រសិទ្ធពរឲ្យសត្វលោកទាំងឡាយ អាចយល់នូវហេតុធម៌ គឺធម៌ស្ដីអំពីការទាក់ទងរវាងហេតុនិងផល ហើយកុំឲ្យសត្វលោកធ្វេសប្រហែសនឹងធម៌នេះឲ្យសោះ។

ដូច្នេះហើយ សេចក្ដីអាសូររបស់ព្រះពុទ្ធគ្របដណ្ដប់លើសត្វលោកទូទៅ ហើយសេចក្ដីប្រោសប្រណីជានិច្ចនិរន្តរ៍របស់ព្រះអង្គ គឺសម្រាប់សុភមង្គលនៃសត្វលោកទាំងនោះ។ ព្រះអង្គស្រឡាញ់សត្វលោក ដូចជាមាតាបិតាស្រឡាញ់បុត្រ។ ព្រះអង្គទ្រង់ប្រសិទ្ធពរឲ្យសត្វលោកទាំងនោះ បានប្រកបដោយសុភមង្គលខ្ពស់បំផុត ពោលគឺៈ ឲ្យបានឆ្លងផុតពីមហាសមុទ្រវដ្ដសង្សារ វិលកើតវិលស្លាប់នេះ។

II

# ការសង្គ្រោះរបស់ព្រះពុទ្ធ និង របៀបស្រោចស្រង់របស់ព្រះអង្គ

1. ដើម្បីឲ្យពុទ្ធវាចា ដែលចេញពីត្រើយដ៏សែនឆ្ងាយនៃពន្លឺត្រាស់ដឹង អាចទៅដល់សត្វលោកដែលកំពុងប្រយុទ្ធពុះពារមិនចេះចប់ក្នុងលោក ពោរពេញទៅដោយការភាន់ច្រឡំនោះ

ជាការពិបាកពន់ពេកណាស់។ ដូច្នេះហើយបានជា ព្រះពុទ្ធទ្រង់វិលត្រឡប់មកក្នុងលោកនេះវិញ ហើយអនុវត្តរបៀបស្រោចស្រង់របស់ព្រះអង្គ។

ព្រះអង្គទ្រង់មានពុទ្ធដីកាថា: «នៅពេលនេះ តថាគតនឹងនិទានរឿងឧបមាមួយឲ្យអ្នកទាំងឡាយស្ដាប់»។ «នាកាលនោះ មានមហាសេដ្ឋីម្នាក់ ត្រូវភ្លើងឆេះផ្ទះ។ នៅពេលភ្លើងឆេះផ្ទះនោះ មហាសេដ្ឋីពុំបាននៅផ្ទះទេ។ នៅពេលគាត់ត្រឡប់មកវិញ គាត់ឃើញកូនចៅគាត់ កំពុងជក់ចិត្តនឹងល្បែងលែងរបស់វា វាពុំបានចាប់ភ្ញាក់នឹងភ្លើងកំពុងឆេះទ្រលោមនោះទេ ហើយនៅតែលេងក្នុងផ្ទះនោះ ពុំគិតរត់ចេញឡើយ។ ឪពុកក៏ស្រែកថា: «កូនចៅទាំងឡាយ ប្រញាប់រត់ចេញពីផ្ទះឲ្យឆាប់ឡើង ! »។ តែក្មេងទាំងនោះ ពុំបានយកចិត្តស្ដាប់បញ្ជារបស់គាត់ទេ។

ដោយហេតុនោះ ឪពុកដែលភ័យខ្លាំង ក៏ស្រែកឡើងម្ដងទៀត: «កូនទាំងឡាយ អញមានប្រដាប់លេងល្អណាស់ នៅឯនេះនែ៎ ចូរនាំគ្នាចេញពីផ្ទះមកយកភ្លាមទៅ ! »។ លើកនេះក្មេងទាំងនោះ ក៏ចាប់ភ្ញាក់នឹងសំឡេងស្រែកហៅរបស់ឪពុកវា

*ហើយក៏នាំគ្នារត់ចេញពីផ្ទះដែលភ្លើងកំពុងឆេះទ្រលោមនោះអស់ទៅ»។*

*លោកនេះ គឺផ្ទះដែលត្រូវភ្លើងកំពុងឆេះទ្រលោមសន្ធោសន្ធៅនោះឯង។ តែសត្វលោក ដែលមិនដឹងខ្លួនមិនចាប់ភ្ញើកនឹងអគ្គីភ័យក្នុងផ្ទះនោះ កំពុងតែរស់នៅក្នុងគ្រោះថ្នាក់ធំដោយនឹងត្រូវភ្លើងឆេះពេលដល់ក្ដីមរណៈ។ ដោយហេតុនេះព្រះពុទ្ធ ដោយព្រះអង្គទ្រង់មានសេចក្ដីអាសូរ ក៏នឹកគិតរកមធ្យោបាយដើម្បីសង្គ្រោះសត្វលោកទាំងនោះ។*

2. *ព្រះពុទ្ធមានពុទ្ធដីកាថា: «តថាគតនឹងនិទានរឿងប្រៀបធៀបមួយទៀត ឲ្យអ្នកទាំងឡាយស្ដាប់។ មានថ្ងៃមួយនោះបុត្រតែមួយរបស់មហាសេដ្ឋីម្នាក់ បានរត់ចេញពីគេហដ្ឋានរបស់ខ្លួន ហើយធ្លាក់ខ្លួនទៅក្នុងក្ដីទុក្ខវេទនាក្រៃលែង។*

*ឪពុកបានចេញពីផ្ទះទៅតាមរកកូន តែត្រូវវង្វេងផ្លូវគ្នាបាត់ដានអស់ទៅ។ ឪពុកបានខិតខំយ៉ាងអស់សមត្ថភាព ដើម្បីរកកូនឲ្យឃើញ តែគ្មានបានលទ្ធផលសោះ។*

*នៅពេលនោះ បុត្រមហាសេដ្ឋីដែលធ្លាក់ខ្លួនរងទុក្ខវេទនា*

នោះ បានដើរវង្វេងវិលវល់នៅជិតកន្លែងដែលឪពុករស់នៅ។

ឪពុកក៏ស្គាល់ជាក់ជាកូនរបស់ខ្លួនភ្លាម ហើយបង្គាប់ខ្ញុំបម្រើឲ្យទៅនាំក្មេងអនាថានោះមក។ ក្មេងអនាថានោះដោយរំភើបនឹងភាពរុងរឿងនៃមហាគ្រឹះស្ថាន និងដោយខ្លាចខ្ញុំបម្រើនោះមើលងាយ ពុំចង់ទៅតាមខ្ញុំបម្រើអស់ទាំងនោះទេ។

ឪពុកបានប្រើខ្ញុំបម្រើឲ្យទៅម្តងទៀត ដោយបង្គាប់ថាឲ្យៗ ប្រាក់កាសខ្លះដល់កូននោះ បើវាចង់ធ្វើជាអ្នកបម្រើក្នុងផ្ទះម្នាក់របស់មហាសេដ្ឋីដែរ។ លើកនេះ កូននោះក៏ព្រមទៅជាមួយនឹងខ្ញុំបម្រើទាំងនោះ ហើយនៅបម្រើក្នុងផ្ទះមហា-សេដ្ឋីនោះទៅ។

ឪពុកបានតម្លើងឋានន្តរស័ក្តិជាលំដាប់លំដោយ រហូតដល់ប្រគល់ទ្រព្យសម្បត្តិ និងឃ្លាំងរតនវត្ថុទាំងអស់ឲ្យគ្រប់គ្រងមើលថែរក្សា តែក្មេងនោះនៅតែមិនស្គាល់ថា ជាឪពុកបង្កើតរបស់ខ្លួនទេ។

ឪពុកសប្បាយចិត្តណាស់ ដោយបានឃើញការស្មោះត្រង់

របស់កូន ហើយនៅពេលអវសាននៃជីវិតជិតមកដល់ហើយនោះ គាត់ក៏ប្រជុំគ្រប់សមាជិកគ្រួសារ និងមិត្តភក្តិទាំងអស់ ហើយមានវាចាថា: «នេះហើយជាកូនតែមួយគត់របស់ខ្ញុំ ដែលខ្ញុំខំដើររកអស់ជាច្រើនឆ្នាំមកហើយ។ អំណើះតទៅ ទ្រព្យសម្បត្តិ និងឃ្លាំងកំណប់របស់ខ្ញុំទាំងអស់ នឹងបានជាកម្មសិទ្ធិរបស់កូននេះ។»

កូនក៏ភ្ញាក់នឹងការប្រកាសរឿងសម្ងាត់នេះ ហើយស្រដីថា: «ខ្ញុំមិនគ្រាន់តែបានជួបនឹងឪពុកវិញប៉ុណ្ណោះទេ តែរហូតបានទទួលទ្រព្យសម្បត្តិ និងឃ្លាំងកំណប់ទាំងអស់របស់គាត់ទៀតក្នុងពេលនេះ»។

ក្នុងរឿងប្រៀបធៀបនេះ មហាសេដ្ឋីជាតំណាងព្រះពុទ្ធ ហើយបុត្រអនាថាជាតំណាងសត្វលោកទាំងអស់។ សេចក្ដីអាសូររបស់ព្រះពុទ្ធ គ្របដណ្ដប់ទូទៅលើសត្វលោកទាំងអស់ដូចជាសេចក្ដីស្នេហារបស់ឪពុក ចំពោះកូនតែមួយរបស់ខ្លួនអញ្ចឹងដែរ។ ក្នុងសេចក្ដីស្នេហានេះ ព្រះពុទ្ធបាននឹកគិតរកគ្រប់មធ្យោបាយទាំងអស់ ដែលប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ ដើម្បីនាំផ្លូវមនុស្សលោក ប្រៀនប្រដៅមនុស្សលោក និងធ្វើឲ្យមនុស្សលោកបានចម្រុងចម្រើន ដោយសម្បត្តិគតិធម៌។

3. «ភ្លៀងធ្លាក់មកប្រោះព្រំរុក្ខជាតិទាំងឡាយស្មើៗ គ្នា យ៉ាង ណា សេចក្តីអាសូររបស់ព្រះពុទ្ធក៏គ្របដណ្តប់លើ សត្វលោក ទាំងឡាយយ៉ាងស្មើៗភាពគ្នាដូចនោះដែរ។ តែក៏ដូចជា រុក្ខ-ជាតិផ្សេងៗគ្នា ដែលទទួលអត្ថប្រយោជន៍ផ្សេងៗ ខុសគ្នាអំពី ភ្លៀងមួយមេដដែលនោះយ៉ាងណា សត្វលោកទាំងឡាយ ដែលមានភាពខុសៗគ្នា និងដែលនៅក្នុងទេសកាលផ្សេងៗគ្នា នោះ ក៏ត្រូវបានទទួលពុទ្ធពរតាមដោយរបៀបផ្សេងៗ ខុសគ្នា យ៉ាងនោះដែរ»។

4. មាតាបិតាស្រឡាញ់កូនទាំងអស់របស់ខ្លួនស្មើៗគ្នា តែសេចក្តី ស្នេហានោះចេញឲ្យឃើញឡើងព្រមជាមួយភាពថ្នាក់ថ្នម ជាពិសេសចំពោះកូនណាដែលមានជំងឺ។

សេចក្តីអាសូររបស់ព្រះពុទ្ធ ក៏មានភាពស្មើគ្នា ចំពោះ សត្វលោកទាំងអស់ដូចនោះដែរ ហើយបញ្ចេញឲ្យឃើញ ឡើង ព្រមជាមួយនឹងការថ្នាក់ថ្នម ជាពិសេសចំពោះមនុស្ស ណាដែលរងទុក្ខវេទនាជាទម្ងន់ដោយសារសេចក្តីល្ងង់ខ្លៅ។

ព្រះអាទិត្យរះឡើងពីទិសខាងកើត ហើយកំចាត់អន្ធភាព

នៃពិភពលោក ដោយមិនបានគិតទុកជាមុន ឬក៏មានអនុគ្រោះនិយមទៅលើតំបន់ណាមួយជាពិសេសនោះទេ។ យ៉ាងណាមិញ សេចក្ដីអាសូររបស់ព្រះពុទ្ធ នៅព័ទ្ធជុំវិញសត្វលោកទាំងអស់ ជួយជម្រុញនិងបំភ្លឺសត្វលោកទាំងនោះឲ្យប្រកាន់យកអ្វីដែលត្រូវ ហើយវៀរចាកអ្វីដែលខុស ក៏យ៉ាងនោះដែរ។ ព្រះអង្គទ្រង់កម្ចាត់អន្ធភាពនៃសេចក្ដីល្ងង់ខ្លៅ ហើយដឹកនាំសត្វទៅកាន់ពន្លឺត្រាស់ដឹង។

ព្រះពុទ្ធជាបិតាម្នាក់ក្នុងសេចក្ដីអាសូររបស់ព្រះអង្គ និងជាមាតាម្នាក់ក្នុងចិត្តល្អប្រពៃពោរពេញទៅដោយ សេចក្ដីអាណិតស្រឡាញ់របស់ព្រះអង្គ។ សត្វលោក ដោយលុះក្នុងការល្ងង់ខ្លៅ និងក្នុងការទាក់ចិត្តនឹងចំណង់លោកិយនោះតែងតែប្រព្រឹត្តអំពើផ្សេងៗ យ៉ាងជប់ជល់ហួសហេតុ។ ដូច្នេះព្រះពុទ្ធក៏រឹតតែមានសេចក្ដីអាសូរចំពោះសត្វលោក កាន់តែខ្លាំងឡើងដែរ។ មនុស្សលោកគ្មានអ្វីជាជំនួយទេ បើគ្មានសេចក្ដីអាសូររបស់ព្រះពុទ្ធ។ មនុស្សលោកក្នុងឋានៈជាកូនចៅរបស់ព្រះពុទ្ធ ត្រូវតែទទួលយករបៀបស្រោចស្រង់របស់ព្រះពុទ្ធអង្គ។

III

# ព្រះពុទ្ធអមតៈ

1. *មនុស្សសាមញ្ញទាំងឡាយជឿថា ព្រះពុទ្ធទ្រង់មានកំណើតជាក្សត្រ ហើយបានសម្រេចសម្ពោធិញ្ញាណក្នុងពេលដែលព្រះអង្គចាកចោលព្រះរាជដំណាក់ ហើយប្រកាន់យកជីវភាពជាសមណៈម្នាក់។ តែតាមពិត គឺជាការរៀបចំទុកមុនតាំងពីអតីតកាលដ៏យូរលង់ណាស់មកហើយ ព្រោះថា ព្រះពុទ្ធបានឋិតនៅជានិច្ចក្នុងពិភពលោកមួយដែលគ្មានទីចាប់ផ្ដើមនិងគ្មានទីបញ្ចប់។*

*ក្នុងសភាពជាព្រះពុទ្ធអមតៈ ព្រះអង្គទ្រង់បានយល់អំពីមនុស្សគ្រប់ប្រភេទទាំងអស់ ហើយព្រះអង្គបានអនុវត្តវិធីស្រោចស្រង់គ្រប់បែបយ៉ាងទាំងអស់។*

*នៅក្នុងព្រះធម៌ដែលឋិតថេររហូតនោះ គ្មានសេចក្ដីបញ្ឆោតបន្លំទេ ព្រោះព្រះពុទ្ធយល់ច្បាស់នូវភាពពិតនៃវត្ថុទាំងអស់ក្នុងលោកនេះ ហើយព្រះអង្គពន្យល់ប្រាប់ទៅគ្រប់សត្វលោកតាមតែសភាពនោះឯង។*

*តាមការពិត ការរកឲ្យយល់នូវលោកនេះ ក្នុងភាពពិតរបស់វា ជាការពិបាកណាស់ ព្រោះថា ថ្វីបើលោកនេះ*

មើលទៅឃើញដូចជាពិត តែវាពុំពិតសោះ ថ្វីបើមើលទៅឃើញដូចជាពោរពេញទៅដោយមន្ទិល តែវាមិនដូច្នោះសោះ។ បុគ្គលល្ងង់ខ្លៅ មិនអាចយល់ការពិតនៃលោកនេះបានទេ។

មានតែព្រះពុទ្ធទេ ដែលយល់យ៉ាងជាក់ច្បាស់នូវលោកនេះក្នុងសភាពពិតរបស់វា ហើយព្រះអង្គមិនដែលថ្លែងអះអាងថា លោកនេះពិតឬជាភពបំភាន់ភ្នែក លោកនេះល្អឬអាក្រក់នោះម្តងណាទេ។ ព្រះអង្គទ្រង់ចង្អុលបង្ហាញអំពីលោកយើងនេះក្នុងសភាពរបស់វាតែប៉ុណ្ណោះ។

អ្វីដែលព្រះពុទ្ធទ្រង់ប្រៀនប្រដៅនោះគឺយ៉ាងនេះ៖ សត្វលោកទាំងឡាយត្រូវតែបណ្តុះឫសគុណធម៌តាមសភាពរបស់ខ្លួនតាមអំពើរបស់ខ្លួន និងតាមជំនឿរបស់ខ្លួន។ ការប្រៀនប្រដៅនេះ វិសេសវិសាលបំផុត គួរតែលោកនេះទទួលយកដោយឥតប្រកែក។

2. ព្រះពុទ្ធប្រៀនប្រដៅមិនត្រឹមតែតាមវាចាសំដីតែប៉ុណ្ណោះទេ ព្រះអង្គថែមទាំងបានប្រៀនប្រដៅតាមជីវិតផ្ទាល់

របស់ព្រះអង្គទៀតផង។ ថ្វីបើជីវិតរបស់ព្រះអង្គគ្មានទីអវសាន យ៉ាងនេះក៏ដោយ ព្រះអង្គទ្រង់បានប្រើគ្រប់មធ្យោបាយការកើត និងការស្លាប់ ដើម្បីដាស់សតិអារម្មណ៍សត្វលោកដែលជាប់ជំពាក់នឹងជីវភាពលោកលន់នៃលោកនេះ។

មានគ្រូពេទ្យម្នាក់ ពេលដែលគាត់មិននៅផ្ទះ បុត្រទាំងអស់របស់គាត់ បាននាំគ្នាផឹកថ្នាំពុលដោយចៃដន់។ នៅពេលត្រឡប់មកដល់ផ្ទះវិញ គ្រូពេទ្យនោះឃើញកូនគាត់ឈឺពុល ក៏ផ្សំថ្នាំឲ្យផឹកបន្សាប។ កូនខ្លះដែលមិនពុលខ្លាំង ក៏ទទួលថ្នាំនោះផឹកហើយបានជាទៅ។ តែកូនខ្លះទៀត ដោយពុលខ្លាំងពេក មិនព្រមផឹកថ្នាំនោះទេ។

លោកគ្រូពេទ្យ ដោយមានសេចក្តីស្នេហាចំពោះបុត្រក៏សម្រេចចិត្តប្រើឧបាយកលដ៏ហ្លួសហេតុមួយ ដើម្បីឲ្យកូនរបស់លោកបានជាអំពីជំងឺពុលនោះ។ លោកឧទានទៅកូនទាំងអស់ថា: «អញត្រូវធ្វើដំណើរទៅឆ្ងាយ។ អញចាស់ហើយមិនដឹងជាស្លាប់ក្នុងថ្ងៃណាទេ»។ បើអញនៅជាមួយឯងទាំងអស់គ្នា អញអាចនឹងថែទាំឯងទាំងអស់គ្នាបាន តែបើអញស្លាប់ទៅ ឯងទាំងអស់គ្នាមុខជានឹងឈឺធ្ងន់ជាងនេះទៅទៀត។

បើឯងទាំងឡាយបានដឹងថាអញស្លាប់ហើយ អញសុំឲ្យឯងរាល់គ្នាផឹកថ្នាំបន្សាបនេះ ហើយឲ្យជាពោគពុលនេះដោយស័ក្តិសិទ្ធិ»។ និយាយចប់ហើយ លោកគ្រូពេទ្យក៏ចេញដំណើរដ៏ឆ្ងាយនោះបាត់ទៅ។ ទៅបាត់បានយូរបន្តិចថ្ងៃមួយ លោកគ្រូពេទ្យប្រើអ្នកនាំសារម្នាក់ ឲ្យមកប្រាប់កូនទាំងឡាយរបស់គាត់ថា គាត់ស្លាប់ហើយ។

កូនទាំងនេះសោកសង្រេងជាខ្លាំងនឹងដំណឹងមរណភាពឪពុក ហើយនិងដឹងខ្លួនថា ពីថ្ងៃនេះទៅ នឹងលែងបានទទួលការបីបាច់រក្សាថ្នាក់ថ្នមពីឪពុកទៀតហើយ។ ដោយនឹកឃើញទៅដល់បណ្តាំចុងក្រោយរបស់ឪពុក និងដោយមានសេចក្តីទុក្ខសោក និងអស់សង្ឃឹម កូនទាំងនោះក៏លេបថ្នាំបន្សាបនោះហើយបានជាសះស្បើយទៅ។

មិនត្រូវដាក់ទោសលោកគ្រូពេទ្យឪពុក ដែលបានបោកបញ្ឆោតកូនៗនោះឡើយ។ ព្រះពុទ្ធប្រៀបបានទៅគ្រូពេទ្យឪពុកនោះឯង: ព្រះអង្គបានប្រឌិតរឿងកើតនិងស្លាប់នេះយកមកប្រើជាឧបាយ ដើម្បីសង្គ្រោះសត្វលោកដែលលង់ក្នុងទាសូបនីយភាពនៃចំណង់។

# ចំពូកទី ៣

# ទ្រង់ទ្រាយ និងលក្ខណៈរបស់ព្រះពុទ្ធ

## I

## ទ្រង់ទ្រាយបីក្នុងអង្គកាយព្រះពុទ្ធ

1. *ចូរកុំស្វែងរកឲ្យស្គាល់ព្រះពុទ្ធតាមរយៈទម្រង់រាងកាយឬកេតនភណ្ឌរបស់ព្រះអង្គនោះឡើយ ព្រោះទម្រង់រូបកាយក្តី កេតនភណ្ឌទាំងឡាយក្តី ពុំមែនជាព្រះពុទ្ធពិតប្រាកដទេ។ ព្រះពុទ្ធពិតប្រាកដគឺ សម្ពោធិញ្ញាណ ឬការត្រាស់ដឹងនោះឯង។*

*វិធីពិតប្រាកដដែលនាំឲ្យស្គាល់ព្រះពុទ្ធ គឺការធ្វើឲ្យបានសម្រេចការត្រាស់ដឹងនោះឯង។*

*បើសិនជាបុគ្គលណាម្នាក់បានឃើញរូបតំណាងព្រះពុទ្ធដ៏ល្អវិសេស ហើយនឹកគិតថាខ្លួនបានស្គាល់ព្រះពុទ្ធ គឺបុគ្គលនោះធ្លាក់ក្នុងភាពភាន់ច្រឡំដោយភ្នែកល្ងិតល្ងង់ហើយ ព្រោះព្រះពុទ្ធពិតប្រាកដ មិនអាចបញ្ចូលខ្លួនទៅក្នុងទម្រង់រូបណាមួយបានទេឬ អាចឲ្យមើលឃើញដោយភ្នែកមនុស្សលោក*

នោះក៏ទេដែរ។ ទោះបីការពិពណ៌នាអំពីកេតនភណ្ឌព្រះពុទ្ធ នោះធ្វើឡើងដ៏ល្អិតល្អន់ឥតខ្ចោះយ៉ាងណាក៏ដោយ ក៏គ្មានជនណាម្នាក់អាចយល់ពីព្រះពុទ្ធបានដែរ។ បានសេចក្តីថា ការធ្វើពិពណ៌នាអំពីកេតនភណ្ឌព្រះពុទ្ធ តាមដោយពាក្យសម្តីមនុស្សលោក ជាការពុំអាចធ្វើបាន។

ថ្វីបើយើងនិយាយអំពីទម្រង់រូបរបស់ព្រះអង្គ ព្រះពុទ្ធអរហន្តគ្មានទ្រង់ទ្រាយច្បាស់លាស់ទេ តែព្រះអង្គអាចបញ្ចេញឲ្យឃើញបានតាមគ្រប់ទម្រង់។ ថ្វីបើយើងធ្វើការពិពណ៌នាអំពីកេតនភណ្ឌព្រះអង្គ ព្រះពុទ្ធអរហន្តគ្មានកេតនភណ្ឌជាក់ច្បាស់ទេ តែព្រះអង្គអាចបញ្ចេញឲ្យឃើញបានតាមគ្រប់កេតនភណ្ឌដ៏វិសេស។

ដូច្នេះហើយ បើបុគ្គលណាឃើញយ៉ាងជាក់ច្បាស់នូវទ្រង់ទ្រាយព្រះពុទ្ធ ឬយល់យ៉ាងជាក់ច្បាស់នូវកេតនភណ្ឌរបស់ព្រះពុទ្ធ ហើយប៉ុន្តែមិនជំពាក់ចិត្តទៅនឹងទ្រង់ទ្រាយ ឬកេតនភណ្ឌទាំងនោះទេ បុគ្គលនោះឈ្មោះថា មានសមត្ថភាពអាចមើលឃើញ និងយល់ព្រះពុទ្ធបាន។

2. អង្គកាយព្រះពុទ្ធ គឺការត្រាស់ដឹង ឬសម្ពោធិញ្ញាណនោះឯង។ ដោយគ្មានរូបរាងនិងគ្មានធាតុ ព្រះពុទ្ធមានស្ថិតនៅ ហើយនឹងស្ថិតនៅតទៅទៀតជានិច្ច។ មិនមែនជាអង្គកាយដែលត្រូវតែទទួលការចិញ្ចឹមបីបាច់ ដោយសារចំណីអាហារនោះទេ គឺជាអង្គកាយអមតៈ ដែលមានព្រហ្មចារិភាពជាធាតុ។ ហេតុដូច្នេះ ព្រះពុទ្ធគ្មានការភ័យ ឬព្រួយបារម្ភអ្វីទេៈ ព្រះអង្គមិនប្រែប្រួលរហូត។

ហេតុនេះ ព្រះពុទ្ធមិនរលត់បាត់ទេ ដរាបណាការត្រាស់ដឹងនៅមាននោះ។ ការត្រាស់ដឹងចេញស្តែងឡើងជាពន្លឺនៃព្រហ្មចារិភាព ដែលដាស់សតិសត្វលោកឲ្យភ្ញាក់ស្វាងក្នុងជីវិតថ្មីមួយ ហើយនិងដែលបណ្តាលឲ្យសត្វលោកទាំងនោះបានទៅកើតឡើងវិញក្នុងភពព្រះពុទ្ធ។

នរជនណា ដែលយល់ច្បាស់សេចក្តីនេះ នឹងបានជាកូនចៅរបស់ព្រះពុទ្ធ។ គឺនរជនទាំងនោះ ប្រតិបត្តិតាមព្រះធម៌ គោរពធ្វើតាមសេចក្តីប្រៀនប្រដៅរបស់ព្រះអង្គ ហើយបញ្ជូនការប្រៀនប្រដៅទាំងនោះទៅឲ្យនរជនជំនាន់ក្រោយៗទៀត។ គ្មានអ្វីដែលអស្ចារ្យជាងឥទ្ធិពលព្រះពុទ្ធទេ។

3. *ព្រះពុទ្ធមានអង្គកាយបី គឺៈ **ធម្មកាយ** ដែលជាទិដ្ឋភាពនៃសារធម៌របស់ព្រះអង្គ១ **សព្វង្គកាយ** ឬរូបកាយ ដែលជាទិដ្ឋភាពនៃចិត្តដ៏វិសេសរបស់ព្រះអង្គ១ និងនាមកាយដែលជាទិដ្ឋភាពនៃការសម្ដែងចេញឲ្យឃើញឡើងរបស់ព្រះអង្គ១។*

***ធម្មកាយ*** *គឺជាខ្លឹមសារនៃព្រះធម៌ គឺជាខ្លឹមសារនៃការពិតនោះតែម្ដង។ ក្នុងភាពជាខ្លឹមនៃព្រះធម៌ ព្រះពុទ្ធគ្មានរូបរាង និងពណ៌សម្បុរទេ ហើយដោយព្រះអង្គគ្មានរូបរាង និងពណ៌សម្បុរនេះ ព្រះអង្គគ្មានចេញមកពីទីណា ហើយទៅទីឯណាទេ។ ដូចជាផ្ទៃមេឃដែលមានពណ៌ខៀវ ព្រះអង្គទ្រង់គ្របពាសលើគ្រប់វត្ថុធាតុទាំងអស់ ហើយដោយព្រះអង្គជាវត្ថុគ្រប់ទាំងអស់នោះ ព្រះអង្គគ្មានខ្វះអ្វីទាំងអស់។*

*ព្រះពុទ្ធមិនមានស្ថិតនៅដោយសារតែមនុស្សទាំងឡាយគិតថាមានព្រះពុទ្ធនោះទេ ហើយព្រះអង្គក៏មិនរលត់ទៅបាត់ដោយសារតែមនុស្សទាំងឡាយភ្លេចនឹកគិតដល់ព្រះអង្គក៏ទេដែរ។ ព្រះអង្គពុំបានទទួលការបង្ខំជាពិសេសណាមួយថា ត្រូវតែចេញស្ដែងឡើង នៅពេលណាសត្វលោកមានសេចក្ដីសុខស្ងប់នោះទេ ហើយព្រះអង្គក៏គ្មានការចាំបាច់ថា ត្រូវតែរលត់*

បាត់ទៅនៅពេលណាសត្វលោកធ្វេសប្រហែស ព្រងើយកន្តើយនោះទេ។ ព្រះពុទ្ធគឺហួសវិស័យមនុស្សគិត។

ក្នុងទ្រង់ទ្រាយនេះ រូបកាយរបស់ព្រះពុទ្ធនៅពាសពេញគ្រប់ចន្លោះទីនៃសកលលោក ព្រះអង្គគង់នៅគ្រប់ទិសទីព្រះអង្គឋិតនៅជានិច្ច ទោះបីមនុស្សលោកជឿថាតាម ឬមានការសង្ស័យចំពោះអត្ថិភាពព្រះអង្គក៏ដោយ។

4. ***សព្វង្គកាយ*** គឺជាសភាពនៃព្រះពុទ្ធ ដែលជាការរលាយចូលគ្នានៃសេចក្ដីអាសូរ និងព្រហ្មចារិភាព ដែលជាវិញ្ញាណឥតរូបភាព ដែលបញ្ចេញឲ្យឃើញឡើងតាមនិមិត្តរូបនៃការកើត និងការស្លាប់ ហើយនិងតាមការធ្វើសច្ចាធិដ្ឋាន ការប្រតិបត្តិ និងការប្រកាសពិសិដ្ឋនាមព្រះអង្គ ដើម្បីដឹកនាំសត្វលោកទាំងអស់ទៅដាក់ដល់ស្ថានផុតទុក្ខ។

យ៉ាងដូច្នេះហើយ សេចក្ដីមហាអាសូរជាខ្លឹមសារនៃរូបកាយព្រះអង្គ ហើយនៅក្នុងគោលគំនិតព្រះអង្គ ព្រះអង្គទ្រង់ប្រើប្រាស់វិធីគ្រប់បែបយ៉ាង ដើម្បីរំដោះជនទាំងឡាយណាដែលប្រុងប្រៀបខ្លួនទទួលការរំដោះនោះ។ ដូចជាក្មេងកាល

ណាឆេះហើយ វាមិនរលត់ទេ ដរាបណាប្រេងមិនទាន់អស់យ៉ាងណាមិញ សេចក្តីអាណិតរបស់ព្រះពុទ្ធមិនមានការរួញរាជានិច្ចដរាបណាតណ្ហាមនុស្សលោកមិនទាន់ចប់អស់។ ដូចជាខ្យល់ដែលបក់ផាត់ធូលី សេចក្តីអាសូររបស់ព្រះពុទ្ធ នៅក្នុងសភាពនេះ កំចាត់ធូលីនៃទុក្ខរបស់មនុស្សលោក។

**នាមកាយ** មានន័យថា ដើម្បីបំពេញការរំដោះទុក្ខដែលព្រះអង្គបានប្រទានតាមសព្វង្គកាយនោះ ព្រះពុទ្ធទ្រង់បានបញ្ចេញឲ្យឃើញដោយរូបរាងពិតនៅក្នុងលោកនេះ ហើយពន្យល់បង្ហាញសត្វលោកអំពីទិដ្ឋភាពនៃការកើត ការលះបង់លោកិយ និងការបានសម្រេចការត្រាស់ដឹង សម្របទៅតាមសភាពនិងសមត្ថភាពនៃសត្វលោក។ ដើម្បីនឹងដឹកនាំសត្វលោក ព្រះពុទ្ធនៅក្នុងសភាពអង្គកាយនេះ ព្រះអង្គទ្រង់ប្រើប្រាស់មធ្យោបាយគ្រប់បែបយ៉ាង ដូចជាការឈឺនិងការស្លាប់ជាដើម។

ទ្រង់ទ្រាយព្រះពុទ្ធ ជាដើមដំបូង គឺធម្មកាយ តែមួយគត់។ តែដោយសភាពសត្វលោកផ្លាស់ប្តូរផ្សេងៗគ្នា រូបភាពរបស់ព្រះពុទ្ធក៏ចេញស្តែងឡើងក្នុងសភាពផ្សេងៗ គ្នាទៅតាមនោះ។ តែទោះបីជារូបភាពព្រះពុទ្ធផ្លាស់ប្តូរ ទៅតាម

ចំណង់ផ្សេងៗគ្នា អំពើផ្សេងៗគ្នា និងសមត្ថភាពផ្សេងៗគ្នានៃសត្វលោកក៏ដោយ ព្រះពុទ្ធបានសេចក្តីថាការពិតនៃព្រះធម៌តែមួយប៉ុណ្ណោះ។

ទោះបីព្រះពុទ្ធមានរូបកាយបីក៏ដោយ ព្រះអង្គទ្រង់មានគោលបំណងតែមួយគត់ គឺស្រោចស្រង់សត្វលោកទាំងអស់។

ទោះបីនៅគ្រប់កាលៈទេសៈ ព្រះពុទ្ធទ្រង់បញ្ចេញឲ្យឃើញក្នុងសភាពបរិសុទ្ធឥតខ្ចោះក៏ដោយ ការបញ្ចេញឲ្យឃើញនេះពុំមែនព្រះពុទ្ធទេ ពីព្រោះព្រះពុទ្ធពុំមែនជារូបរាងណាមួយទេ។ សភាពព្រះពុទ្ធបំពេញនៅគ្រប់វត្ថុទាំងអស់ព្រះអង្គបង្កើតអង្គកាយរបស់ព្រះអង្គផ្ទាល់ ពីការត្រាស់ដឹង ហើយក្នុងភាពជាការបានដល់នូវការត្រាស់ដឹងនេះ ព្រះអង្គទ្រង់បានបញ្ចេញឲ្យឃើញចំពោះគ្រប់ជនណា ដែលអាចយល់នូវសេចក្តីពិត។

II

## ការបញ្ចេញឲ្យឃើញនៃព្រះពុទ្ធ

1. គឺជាការកម្របំផុតដែលបានព្រះពុទ្ធមួយអង្គមកចាប់កំណើត

ក្នុងលោកនេះ។ កាលបើព្រះពុទ្ធកើតឡើងហើយ ព្រះអង្គបាន សម្រេចការត្រាស់ដឹង ព្រះអង្គបង្កើតព្រះធម៌ ព្រះអង្គជម្រះ សំណាញ់នៃសេចក្តីមន្ទិលសង្ស័យ ព្រះអង្គទ្រង់កម្ចាត់តណ្ហា ទាំងឡាយព្រមទាំងឫស ព្រះអង្គខ្ទប់ផ្លូវបង្វែរនៃទុក្ខ។ ព្រះអង្គ និមន្តសុសសព្វទិសទីក្នុងលោកនេះ តាមតែបំណងព្រះអង្គដោយ ពុំមានឧបសគ្គណាមួយអាចឃាត់ឃាំងព្រះអង្គបានឡើយ។ គ្មាន អ្វីដែលធំជាងការគោរពយ៉ាងជ្រាលជ្រៅចំពោះព្រះពុទ្ធទេ។

ព្រះពុទ្ធចេញឲ្យឃើញ ក្នុងពិភពដែលពោរពេញទៅ ដោយទុក្ខវេទនា ព្រោះព្រះអង្គមិនអាចបោះបង់ចោលនូវសត្វ លោកដែលមានទុក្ខនោះបានទេ។ គោលបំណងតែមួយគត់ របស់ព្រះអង្គគឺ ការផ្សាយព្រះធម៌ និងការធ្វើឲ្យសត្វលោកបាន ប្រកបសុភមង្គលដោយសារសេចក្តីពិតនៃព្រះធម៌នោះ។

ការពន្យល់បង្ហាញព្រះធម៌នៅក្នុងពិភពដែលពោរពេញ ទៅដោយអយុត្តិធម៌និងគុណវិបត្តិ ក្នុងពិភពដែលពុះពារ តស៊ូ ដោយឥតប្រយោជន៍ជាមួយនឹងតណ្ហាមិនចេះឆ្អែតឆ្អន់ និង ទុក្ខវេទនាដែលបណ្តាលមកពីតណ្ហានោះ ជាការពិបាកណាស់។ ព្រះពុទ្ធប្រឈមមុខតទល់នឹងឧបសគ្គទាំងនេះ ពីព្រោះតែ

ព្រះអង្គមានសេចក្ដីស្រឡាញ់ និងអាសូរដ៏ធំធេង។

2. ព្រះពុទ្ធជាមិត្តដ៏ល្អចំពោះគ្រប់ជនទាំងអស់ក្នុងលោកនេះ បើព្រះអង្គជួបនឹងបុគ្គលណាមានទុក្ខធ្ងន់ ដោយសារតណ្ហាលោកិយ ព្រះអង្គទ្រង់មានសេចក្ដីអាសូរ ហើយរំលែកនូវបន្ទុកដ៏ធ្ងន់នោះ។ បើព្រះអង្គជួបនឹងបុគ្គលណាមានទុក្ខវេទនា ដោយសារការយល់ច្រឡំ ព្រះអង្គទ្រង់កម្ចាត់ការយល់ច្រឡំនោះដោយពន្លឺដ៏វិសុទ្ធនៃព្រហ្មចារិភាពរបស់ព្រះអង្គ។

ដូចជាកូនគោ ដែលសប្បាយរីករាយនឹងរស់នៅជាមួយមេវា បុគ្គលទាំងឡាយណាដែលបានស្ដាប់ការប្រៀនប្រដៅរបស់ព្រះពុទ្ធ មិនចង់ចាកចេញពីព្រះអង្គទេ ពីព្រោះការប្រៀនប្រដៅទាំងនោះ ផ្ដល់នូវសុភមង្គលដល់បុគ្គលទាំងឡាយនោះ។

3. កាលណាព្រះចន្ទលិចទៅ អ្នកផងតែងថាព្រះចន្ទលិចបាត់ទៅហើយ ហើយកាលណាព្រះចន្ទរះឡើង អ្នកផងតែងថាព្រះចន្ទរះឡើងហើយ។ តែតាមពិត ព្រះចន្ទគ្មានមកពីណា

ឬបាត់ទៅណាទេ ព្រះចន្ទបែងចាំងដោយគ្មានការផ្លាស់ប្តូរនៅលើផ្ទៃមេឃ។ ព្រះពុទ្ធក៏ដូចជាព្រះចន្ទនោះយ៉ាងពិតប្រាកដ ព្រះអង្គគ្មានចេញឡើង ឬបាត់ទៅណាទេ។ ព្រះអង្គធ្វើដូចជាកើតឡើងហើយ រលត់បាត់ទៅយ៉ាងនេះ ដោយសារតែព្រះអង្គស្រឡាញ់សត្វលោក ហើយដើម្បីនឹងអាចប្រៀនប្រដៅសត្វលោកទាំងនោះ។

បុគ្គលទាំងឡាយតែងហៅព្រះចន្ទពេញវង់ថា ជាកាលសម័យមួយ ហើយព្រះចន្ទមួយចំណិតថា ជាកាលសម័យមួយផ្សេងទៀត តែតាមការពិត ព្រះចន្ទមានភាពមូលឥតខ្ចោះជានិច្ច ហើយគ្មាន ខ្នើតឬរនោចទេ។ ព្រះពុទ្ធក៏ពិតដូចជាព្រះចន្ទនោះដែរ។ នៅចំពោះភ្នែកមនុស្សលោក ព្រះពុទ្ធហាក់ដូចជាផ្លាស់ប្តូរភាព តែតាមការពិតព្រះពុទ្ធឥតផ្លាស់ប្តូរទេ។

ព្រះចន្ទចេញឡើងនៅគ្រប់ទិសទី នៅលើក្រុងដែលមានមនុស្សកុះករ នៅលើស្រុកភូមិស្ងាត់ជ្រងំ នៅលើព្រៃភ្នំ នៅលើទន្លេស្ទឹង។ ព្រះចន្ទអាចមើលឃើញនៅក្នុងជម្រៅនៃបាតបឹង នៅក្នុងក្អមទឹក នៅក្នុងដំណក់ទឹកសន្សើម ដែលដក់ជាប់នៅនឹងស្លឹកឈើ។ បើទុកជាអ្នកណាម្នាក់ដើរអស់ប៉ុន្មានរយយោជន៍

ក៏ដោយ ក៏ព្រះចន្ទដើរតាមអ្នកនោះដែរ។ ចំពោះមនុស្សលោក ព្រះចន្ទហាក់ដូចជាផ្លាស់ប្តូរ តែព្រះចន្ទមិនផ្លាស់ប្តូរទេ។ ព្រះពុទ្ធក៏ដូចជាព្រះចន្ទដែរ ព្រះអង្គត្រាច់តាមមនុស្សលោកនេះគ្រប់កាលៈទេសៈ ដែលប្តូរផ្លាស់ព្រះអង្គសម្តែងឲ្យឃើញឡើងក្នុងភាពផ្សេងៗគ្នា តែក្នុងខ្លឹមសារព្រះអង្គៗមិនផ្លាស់ប្តូរទេ។

4. ការណ៍ដែលព្រះពុទ្ធសម្តែងឲ្យឃើញឡើង ឬរលត់បាត់ទៅនោះ អាចពន្យល់បានតាមការទាក់ទងហេតុ និងផលកាលណាហេតុ និងល័ក្ខខ័ណ្ឌនោះសមប្រកប ព្រះពុទ្ធក៏ចេញស្តែងឲ្យឃើញឡើង តែបើសិនជាហេតុនិងល័ក្ខខ័ណ្ឌនោះ មិនសមប្រកបទេ ព្រះពុទ្ធហាក់ដូចជារលត់បាត់ពីលោកនេះទៅ។

ទោះជាព្រះពុទ្ធស្តែងចេញឡើងក្តី ឬរលត់បាត់ទៅក្តី ភាពពិតរបស់ព្រះពុទ្ធនៅដដែលជានិច្ច។ ដោយយល់នូវគោលការណ៍នេះ បុគ្គលម្នាក់ៗត្រូវតែប្រកាន់យកនូវផ្លូវនៃការត្រាស់ដឹង ហើយបានសម្រេចគតិបណ្ឌិតពេញលេញឥតខ្ចោះ មិនមានសេចក្តីរឹកររតក់ស្លុត នឹងការផ្លាស់ប្តូរខាងក្រៅ

នៃទម្រង់ព្រះពុទ្ធ ដែលនិម្មិតឡើងទៅតាមល័ក្ខខ័ណ្ឌនៃលោក នេះ និងទៅតាមដំណើរប្រែប្រួលនៃគតិអារម្មណ៍មនុស្សលោក។

មានសេចក្តីតំណាលពន្យល់ថា ព្រះពុទ្ធពុំមែនជាអង្គរូបវ័ន្តទេ តែគឺជាពន្លឺចែងចាំង ឬការត្រាស់ដឹងនោះឯង។ គេអាចនឹកប្រៀបប្រដូចនូវអង្គមួយទៅនឹងចានប្រជុំពន្លឺ ឬគម្រប់ចង្កៀង។ កាលណាចានប្រជុំពន្លឺនោះ ពេញទៅដោយពន្លឺ ហើយគេអាចហៅចាននោះថា ជាព្រះពុទ្ធបាន។ ហេតុនេះហើយ បើបុគ្គលណាម្នាក់គិតតែពីអង្គរូបវ័ន្តព្រះពុទ្ធ ហើយយំសោក នឹងការបាត់បង់ព្រះពុទ្ធនោះ បុគ្គលនោះនឹងមិនអាច មើលឃើញព្រះពុទ្ធពិតប្រាកដទេ។

ដោយពិត ភាពពិតនៃវត្ថុទាំងអស់ វាហួសពីការដែលមនុស្សលោកបានគិតយល់ និងវែកញែកអំពីការកើតឡើង ហើយបាត់ទៅវិញ អំពីការទៅហើយមក អំពីការល្អ និងអាក្រក់។ វត្ថុទាំងអស់ដូចគ្នាបេះបិទ គឺគ្មានសារជាតិទេ។

ការគិតយល់ និងវែកញែករបស់មនុស្សលោកចំពោះវត្ថុទាំងអស់នោះ គឺដោយសារតែការវិនិច្ឆ័យដោយភាន់ច្រឡំនៃជនទាំងឡាយ ដែលបានឃើញបាតុភូតទាំងនោះតែប៉ុណ្ណោះ

ឯង។ ទ្រង់ទ្រាយពិតរបស់ព្រះពុទ្ធមិនកើតឡើង ឬរលត់ទៅបាត់ទេ។

III

# គុណធម៌របស់ព្រះពុទ្ធ

1. ព្រះពុទ្ធទ្រង់បានទទួលការគោរពអំពីសកលលោកដោយសារគុណធម៌របស់ព្រះអង្គទាំងប្រាំគឺៈ ចរិយាប្រសើរបំផុត ទស្សនៈខ្ពង់ខ្ពស់បំផុត ព្រហ្មចារិភាពឥតខ្ចោះ សមត្ថភាពពេញលេញក្នុងការប្រៀនប្រដៅ និងឥទ្ធិពលក្នុងការដឹកនាំសត្វលោកឲ្យប្រតិបត្តិតាមការប្រៀនប្រដៅរបស់ព្រះអង្គ។

ជាពិសេសទៅទៀត ព្រះពុទ្ធមានគុណធម៌ប្រាំបីផ្សេងទៀត ដែលញុំាងឲ្យព្រះអង្គអាចផ្តល់នូវគុណប្រយោជន៍ និងសុភមង្គលដល់សត្វលោកបានគឺៈ នាំអត្ថប្រយោជន៍ភ្លាមៗមកឲ្យលោកនេះ ដោយសារការប្រតិបត្តិតាមសេចក្តីប្រៀនប្រដៅរបស់ព្រះអង្គ១ វិនិច្ឆ័យយ៉ាងត្រឹមត្រូវអំពីល្អ និងអាក្រក់ អំពីត្រូវនិងខុស១ ដឹកនាំសត្វលោកទៅកាន់ការត្រាស់ដឹង ដោយប្រៀនប្រដៅសត្វលោកទាំងនោះនូវផ្លូវត្រូវ១ ដឹកនាំសត្វលោក

តាមដោយមធ្យោបាយត្រឹមត្រូវ សមរម្យ១ ចៀសវាងអតិ-មានះនិងអំនួត១ ធ្វើអ្វីដែលព្រះអង្គបាននិយាយ១ និយាយអ្វីដែលព្រះអង្គបានធ្វើ១ ហើយដោយបានធ្វើដូច្នេះ ព្រះអង្គបានបំពេញបំណងនៃព្រះទ័យព្រះអង្គ ដែលពោរពេញទៅដោយសេចក្ដីអាសូរ១។

ព្រះពុទ្ធទ្រង់ចម្រើនភាវនា រក្សាចិត្តស្ងប់ស្ងួត ចិត្តដែលជះចេញឡើងជារស្មីនៃសេចក្ដីស្រឡាញ់ សេចក្ដីអាសូរសេចក្ដីសប្បាយចិត្តដែលមានភាពនឹង។ ព្រះអង្គទ្រង់ទុកដាក់សត្វលោកទាំងអស់ក្នុងភាពស្មើគ្នា ព្រះអង្គជម្រះគ្រប់មន្ទិលហ្មងសៅអំពីសតិអារម្មណ៍សត្វលោកទាំងនោះ ហើយនាំមកផ្ដល់ឲ្យសត្វលោកទាំងនោះនូវសុភមង្គល ដែលកើតអំពីឯកភាពព្រលឹងបរិសុទ្ធឥតខ្ចោះ។

2. ព្រះពុទ្ធជាបិតាផង ជាមាតាផង សម្រាប់ជនទាំងឡាយនៃលោកនេះ។ ក្នុងរយៈពេលជប់ប្រាំមួយខែចាប់ពីពេល ដែលកូនក្មេងម្នាក់កើតឡើងមក មាតាបិតាត្រូវតែនិយាយភាសាកូនក្មេងជាមួយនឹងវា ហើយជាលំដាប់បន្តបន្ទាប់មកមាតាបិតា

បង្រៀនក្មេងនោះឲ្យនិយាយដូចមនុស្សចាស់។

ព្រះពុទ្ធ ក៏ដូចជាមាតាបិតាទាំងឡាយក្នុងលោក យើងនេះដែរ។ មុនដំបូងព្រះអង្គថែទាំសត្វលោក រួចហើយ ព្រះអង្គទុកសត្វលោកទាំងនោះឲ្យថែទាំខ្លួនដោយខ្លួនឯង។ មុនដំបូងព្រះអង្គផ្តល់វត្ថុដែលសត្វលោកមានបំណងចង់បាន ជាបន្ទាប់មកព្រះអង្គដឹកនាំសត្វលោកទាំងនោះទៅកាន់ទីជម្រកមួយ ដែលប្រាកដហើយប្រកបដោយសេចក្តីសុខ។

អ្វីដែលព្រះពុទ្ធបង្រៀនតាមភាសារបស់ព្រះអង្គ សត្វ-លោកទាំងឡាយទទួលយកសេចក្តីប្រៀនប្រដៅនោះ ទៅបញ្ចូលឲ្យជ្រួតជ្រាបនៅក្នុងភាសារបស់ខ្លួនផ្ទាល់ ហាក់ដូចជាសេចក្តីប្រៀនប្រដៅនោះទុកសម្រាប់តែខ្លួនឯងម្នាក់។

សភាពវិញ្ញាណរបស់ព្រះពុទ្ធ ផុតហួសពីមនុស្សលោកស្មានគិត។ សតិវិញ្ញាណព្រះពុទ្ធនេះ មិនអាចនឹងយល់បានដោយសារពាក្យសម្តីទេ គេគ្រាន់តែអាចឲ្យជាយោបល់បានទៅតាមឧបមាកថាតែប៉ុណ្ណោះ ចំពោះសតិវិញ្ញាណព្រះពុទ្ធនេះ។

ទឹកស្ទឹងឡើងរំជួយដោយសារតែហ្វូងសេះ និងហ្វូងដំរីរត់ឆ្លងកាត់ ហើយឡើងល្អក់ដោយសារតែហ្វូងត្រីនិងអណ្តើក

ហែបហែលក្នុងស្ទឹងនោះ។ តែទឹកស្ទឹងហូរយ៉ាងបរិសុទ្ធដោយ មិនរឹករវនឹងអប្បគ្ឃវត្ថុពាយរងទាំងនេះទេ។ ព្រះពុទ្ធក៏ដូចជាស្ទឹងធំនេះដែរ។ ហ្វូងត្រី និងអណ្ដើកនៃសិក្ខាបទផ្សេងៗ ៦ ទៀត ហែលនៅក្នុងជម្រៅគង្គាបញ្ច្រាស់នឹងខ្សែទឹកតែជាការឥតប្រយោជន៍។ ធម៌ព្រះពុទ្ធហូរយ៉ាងបរិសុទ្ធដោយមិនមានការរឹករវទេ។

3. ព្រហ្មចារិភាពឥតខ្ចោះរបស់ព្រះពុទ្ធ ចៀសវាងការវិនិច្ឆ័យទុកមុន ដែលធ្វើឡើងដោយហួសប្រមាណហើយរក្សាទុកនូវការទប់ឲ្យនៅជាកណ្ដាល ដែលជាការមួយពុំអាចពិពណ៌នាបានតាមពាក្យសម្ដី។ ដោយព្រះអង្គដឹងគ្រប់ ព្រះពុទ្ធយល់ចិត្តគំនិតមនុស្សលោកទាំងអស់ ហើយយល់ភ្លាមមួយរំពេចនូវគ្រប់វត្ថុទាំងអស់។

ដូចជាហ្វូងតារានៅលើមេឃា ដែលចាំងឆ្លុះទៅក្នុងសមុទ្រដ៏ស្ងប់ គំនិតនិងមនោសញ្ចេតនានៃសត្វលោក ព្រមទាំងទេសកាលទាំងអស់ ក៏ឆ្លុះទៅក្នុងជម្រៅនៃព្រហ្មចារិភាពរបស់ព្រះពុទ្ធយ៉ាងនោះដែរ។ ដូច្នេះហើយបានជាព្រះពុទ្ធ ទ្រង់

មានព្រះនាមថា «បុគ្គលមានពន្លឺបរិបូណ៌ឥតខ្ចោះ» គឺថា «បុគ្គលដឹងគ្រប់»។

ព្រហ្មចារិភាពរបស់ព្រះពុទ្ធ ធ្វើឲ្យវិញ្ញាណសោះកក្រោះនៃសត្វលោកបានល្អឡើងវិញ បំភ្លឺសត្វលោកទាំងនោះ ពន្យល់បង្ហាញសត្វលោកទាំងនោះអំពីន័យនៃលោកនេះ អំពីហេតុនិងផល អំពីការកើតឡើង និងការវិនាសបាត់ទៅវិញ។ សម្រេចទៅ ប្រសិនបើគ្មានព្រហ្មចារិភាពរបស់ព្រះពុទ្ធទេ តើទិដ្ឋភាពនៃលោកនេះ ដែលសត្វលោកអាចយល់បាននោះ វារបៀបណាដែរ ? ។

4. ព្រះពុទ្ធពុំស្តែងចេញជាព្រះពុទ្ធជានិច្ចទេ។ ជួនកាលព្រះអង្គចេញស្តែងឡើងជារូបបិសាច ជួនកាលជាស្ត្រី ជួនកាលជាអាទិទេព ជួនកាលជាមហាក្សត្រ ឬរដ្ឋបុរស ជួនកាលព្រះអង្គចេញស្តែងឡើងនៅក្នុងផ្ទះឧបទ្រព ឬក្នុងរោងល្បែង។

ក្នុងពេលមានជំងឺឆ្លងរាតត្បាត ព្រះអង្គចេញស្តែងជាពេទ្យហ្ម ហើយនៅក្នុងសង្គ្រាម ព្រះអង្គបង្រៀនឲ្យមានសេចក្តីអត់

ធ្មត់ និងឲ្យមានសេចក្តីអាណិតចំពោះអ្នកដែលឈឺចាប់។ ព្រះអង្គទូន្មានអំពីការមិនឋិតថេរ និងការមិនទៀងដល់ជនដែលគិតថា វត្ថុទាំងឡាយឋិតថេររហូត។ ព្រះអង្គទូន្មានអំពីការបេះបន្ទាបខ្លួន និងការបេះផ្ញើពលិកម្ម ចំពោះជនដែលក្រអឺតក្រអោង និងមានអត្តទត្តភាព។ ព្រះអង្គបង្ហាញឲ្យឃើញនូវទុក្ខវេទនានៃលោកនេះ ចំពោះជនណាដែលជាប់ក្នុងសំណាញ់នៃតណ្ហាលោកិយ។

កិច្ចការចាំបាច់របស់ព្រះពុទ្ធ គឺបញ្ចេញខ្លឹមសារដ៏បរិសុទ្ធនៃធម្មកាយ ឬសភាពដាច់ខាតរបស់ព្រះអង្គ នៅក្នុងគ្រប់ករណីនិងកាលៈទេសៈ។ ដូច្នេះហើយ សេចក្តីស្រឡាញ់ និងសេចក្តីអាសូររបស់ព្រះពុទ្ធ សាយចេញអំពីធម្មកាយនោះទៅជាជីវិតមួយ ដែលគ្មានទីអវសាន និងជាពន្លឺមួយដែលគ្មានព្រំដែន ហើយរំដោះសត្វលោកឲ្យផុតអំពីទុក។

5. លោកនេះដូចជាផ្ទះមួយកំពុងត្រូវភ្លើងឆេះ វិនាសខ្ទេចខ្ទីហើយសាងឡើងវិញ កសាងឡើងវិញហើយវិនាសអស់ទៅវិញ គ្មានបេះឈប់ឈរ។ សត្វលោកដោយវិលវល់ក្នុងសេចក្តី

លិ្វតលង់ ត្រូវឡប់សតិទៅក្នុងកំហឹង ក្នុងការមិនចេះពេញចិត្ត ក្នុងសេចក្តីច្រណែននិន្ទា ក្នុងសេចក្តីប្រមាថ និងក្នុងតណ្ហាលោកិយ។ សត្វលោក បីដូចជាកូនក្មេងដែលត្រូវការមាតាជាចាំបាច់ បុគ្គលនីមួយៗត្រូវតែពឹងផ្អែកនឹងសេចក្តីស្នេហារបស់ព្រះពុទ្ធ។

ព្រះពុទ្ធជាបិតា ចំពោះគ្រប់បុគ្គលក្នុងលោកនេះ។ មនុស្សទាំងអស់ជាកូនចៅរបស់ព្រះពុទ្ធ។ ព្រះពុទ្ធបរិសុទ្ធជាងសន្តបុគ្គលទាំងអស់។ លោកយើងនេះ កំពុងឆេះដោយភ្លើងជរា ទុព្វលភាពនិងភ្លើងមរណៈ។ នៅទីណាក៏មានទុក្ខ តែសត្វលោកដែលខំស្វះស្វែងដោយឥតប្រយោជន៍នូវតណ្ហាលោកិយ មិនមានសតិគ្រប់គ្រាន់ដើម្បីបានយល់រឿងនេះទេ ។

ព្រះពុទ្ធបានយល់ឃើញថា ប្រាសាទវិមានដែលពោរពេញទៅដោយការសប្បាយ បើតាមពិតគឺជាផ្ទះដែលកំពុងត្រូវភ្លើងឆេះ។ ហេតុនេះហើយបានជាព្រះអង្គគេចចេញពីទីនោះ ហើយរកឃើញទីជម្រកប្រកបដោយសុខសន្តិភាព នៅក្នុងព្រៃស្ងាត់។ នៅទីស្ងប់ស្ងាត់ដាច់ស្រយាលនោះ ព្រះអង្គទ្រង់បានដល់នូវហឫទ័យមហាអាសូរ ហើយព្រះអង្គទ្រង់មាន

ពុទ្ធដីកាថាៈ «លោកិយដែលប្រែប្រួលនិងពោរពេញទៅដោយទុក្ខវេទនានេះ ជារបស់ផងតថាគត។ អ្នកល្ងង់ខ្លៅអ្នកឆ្កួតវង្វេងទាំងនោះ ជាកូនចៅផងតថាគត។ មានតែតថាគតតែម្នាក់គត់ ដែលអាចស្រោចស្រង់អ្នកទាំងនោះឲ្យរួចផុតពីការយល់ច្រឡំ និងទុក្ខវេទនា»។

ដោយព្រះពុទ្ធជាមហាអធិបតីនៃធម៌ ព្រះអង្គអាចទេសនាប្រៀនប្រដៅសត្វលោកទាំងអស់បានដូចព្រះអង្គប្រាថ្នា។ ដូច្នេះហើយ ព្រះពុទ្ធដែលសម្ដែងឲ្យឃើញឡើងនៅក្នុងលោកនេះ គឺដើម្បីធ្វើឲ្យសត្វលោកបានប្រកបនូវសុភមង្គល ដើម្បីស្រោចស្រង់សត្វលោកទាំងនោះឲ្យរួចផុតពីទុក្ខវេទនា ព្រះអង្គទ្រង់បង្រៀនព្រះធម៌ តែដោយត្រចៀកសត្វលោកវាទន់ទៅតាមសេចក្ដីលោភលន់ សត្វលោកទាំងនោះក៏មិនបានប្រុងស្មារតី។

តែអ្នកដែលស្ដាប់ការទូន្មានរបស់ព្រះអង្គ អាចចាកផុតពីការយល់ច្រឡំទាំងនោះ ហើយរួចផុតពីទុក្ខវេទនានៃជីវិតនេះ។ ព្រះអង្គមានពុទ្ធដីកាថាៈ «សត្វលោកទាំងឡាយមិនអាចសង្គ្រោះអាត្មាឯង ដោយសំអាងលើតែសតិបញ្ញារបស់

ខ្លួនផ្ទាល់នោះបានទេ គឺទាល់តែមានសទ្ធាជ្រះថ្លាចំពោះការប្រៀនប្រដៅរបស់តថាគតផង ទើបបានសម្រេច»។ ហេតុនេះ យើងត្រូវតែស្តាប់ការទូន្មានរបស់ព្រះពុទ្ធ និងប្រតិបត្តិតាមការទូន្មាននោះ៕